# អត្ថន័យនៃ ពិធី លៀងព្រះអម្ចាស់

## ក្នុងក្រុមជំនុំ យូណៃធីតមេថូឌីស្ទ

E. Byron Anderson

# អត្ថន័យនៃពិធីលៀងព្រះអម្ចាស់

## ក្នុង

## ក្រុមជំនុំយូណៃធីតមេថូឌីស្ទ

E. Byron Anderson

Scripture quotations, unless otherwise indicated, are from the New Revised Standard Version of the Bible, copyright © 1989 by the Division of Christian Education of the National Council of the Churches of Christ in the USA. All rights reserved. Used by permission.

THE MEANING OF HOLY COMMUNION IN THE UNITED METHODIST CHURCH. Copyright © 2014 Discipleship Resources. All rights reserved. No part of this book may be reproduced in any form whatsoever, print or electronic, without written permission, except in the case of brief quotations embodied in critical articles or reviews. For information regarding rights and permissions, contact jcrowe@umcdiscipleship.org.

# មាតិការ

សេចក្តីផ្តើម ..... 4
សាក្សីតាមព្រះគម្ពីរ ..... 5
ឈ្មោះ សំរាប់ពិធីលៀងព្រះអម្ចាស់ ..... 8
ព្រះបន្ទូល និងតុព្រះអម្ចាស់ ..... 11
ការអរព្រះគុណ ..... 13
    សំនួរពីការអធិស្ឋាន និងការអរព្រះគុណ ..... 16

មានអ្វីកើតឡើង? ..... 18
វត្ថុមានពិតរបស់ព្រះគ្រីស្ទ ..... 20
តើអ្នកណាអាចទទួលបាន? ..... 22
    សំនួរពីអ្នកដែលអាចទទួល ..... 24

អ្នកណាដែលសាកសម? ..... 26
ញឹកញាប់ប៉ុណ្ណា? ..... 28
    សំនួរពីភាពញឹកញាប់ និងពេលវេលា ..... 30

វិធីនៃការទទួល ..... 32

សំនួរដែលគេសួរញឹកញាប់ផ្សេងទៀត ..... 35
    ការប្រារព្ធពិធីវិសុទ្ធ ..... 36
    អ្នកចាត់ចែង និងពន្ធកិច្ច ..... 41
    ការយកចិត្តទុកដាក់ចំពោះធាតុនៃពិធីវិសុទ្ធ ..... 45

ផ្នែកព្រលឹងវិញ្ញាណនៃពិធីលៀងព្រះអម្ចាស់ ..... 48
សៀវភៅផ្សេងទៀតសំរាប់អាន ..... 49
អំពីអ្នកនិពន្ធ ..... 51

# សេចក្តីផ្តើម

វាជាការល្អ និងបរិសុទ្ធ ដែលត្រូវបានអញ្ជើញចូលរួមក្នុងតុព្រះអម្ចាស់។ សំរាប់អ្នកខ្លះ ការអញ្ជើញនេះធ្វើឲ្យគេនឹកចាំពីពេលវេលាបរិសុទ្ធក្នុងជីវិតរបស់គេ ជាពិសេសគឺទាក់ទងនិងក្រុមជំនុំ និងព្រះគុណអស្ចារ្យរបស់ព្រះ។ សំរាប់អ្នកផ្សេងទៀត វាធ្វើឲ្យគេនឹកចាំពី ការមិនចុះសម្រុងគ្នារបស់ក្រុមជំនុំ៖ ការខ្វះខាតចំពោះការស្វាគមន៍របស់ក្រុមជំនុំខ្លះ សេចក្តីត្រូវការនៃការផ្សះផ្សារក្នុងសហគមន៍ និងគ្រួសារនៃក្រុមជំនុំ ក៏ដូចគ្នារវាងព្រះវិហារ និងព្រះវិហារ និងអំពើបាប និងការបរាជ័យ។ ស្ថានភាពនេះ អញ្ជើញឲ្យយើងពិចារណា ពីការយល់របស់យើង សំរាប់អាហារដ៏វិសុទ្ធនេះ។

កូនសៀវភៅនេះរៀបចំឡើងសំរាប់ណែនាំខ្លីៗ អំពីអត្ថន័យ និងការអនុវត្តន៍ នៃពិធីលៀងព្រះអម្ចាស់ ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ ជាពិសេស ការនេះបានរៀបជាពិធីអាថ៌កំបាំងដ៏បរិសុទ្ធៈ ការយល់ពីពិធីលៀងព្រះអម្ចាស់នៃក្រុមជំនុំយូណៃធីតមេថូឌីស្ទ ដែលបានរៀបចំ ដោយមហាសន្និបាទសកលលោកឆ្នាំ២០០៤ និងកែសម្រួលឆ្នាំ២០១២។ យើងនឹងមើលសំនួរ សំខាន់ៗមួយចំនួន នៃពិធីលៀងព្រះអម្ចាស់៖ តើព្រះគម្ពីរប្រាប់យើងអ្វីខ្លះពីអាហារបរិសុទ្ធ មួយនេះ? តើឈ្មោះផ្សេងៗរបស់ពិធីលៀងព្រះអម្ចាស់ មានន័យដូចម្តេច ហើយតើឈ្មោះទាំងនេះធ្វើឲ្យយល់ដូចម្តេចពីពិធីលៀងព្រះអម្ចាស់? តើបរិបទ និងទំរង់នៃពិធីលៀងព្រះអម្ចាស់ (តាមសៀវភៅចម្រៀង) ធ្វើឲ្យយើងយល់យ៉ាងម៉េចចំពោះកម្មវិធីនេះ? តើអ្នកណាអាចប្រារព្ធឬទទួលពិធីនេះបាន? តើយើងគួរប្រារព្ធពិធីនេះ ញឹកញាប់ប៉ុណ្ណាដែរ? ហេតុអ្វីក្រុមជំនុំផ្សេងគ្នា ធ្វើពិធីនេះដោយរបៀបផ្សេងៗគ្នា? បន្ថែមលើសំនួរនៃអត្ថន័យទាំងនេះ យើងក៏ផ្តល់នូវចំឡើយសំរាប់សំនួរដែលគេសួរញឹកញាប់ ទាក់ទងនិងការអនុវត្តន៍នៃពិធីលៀង ព្រះអម្ចាស់ ជាពិសេសគឺសំនួរដែលថា អ្នកណាជាអ្នកចាត់ចែងពិធីនេះ ហើយអ្នកណាថែរក្សារចំណិតនំបុ័ងនិងទឹកជំពាំងបាយជូរ ហើយនិងរបៀបដែលយើងឆ្លើយតបចំពោះ សម័យបច្ចេកវិទ្យានេះ។



# សាក្សីពីព្រះគម្ពីរ

រឿងក្នុងព្រះគម្ពីរមួយចំនួន ជួយឲ្យយើងយល់ពីពិធីលៀងព្រះអម្ចាស់។ ជាទូទៅយើងសំដៅទៅលើរឿងអាហារដែលព្រះយេស៊ូវធ្វើជាមួយពួកសិស្ស ក្នុងថ្ងៃដែលទ្រង់ត្រូវបានក្បត់ (ម៉ាថាយ ២៦៖១៧-៣០; ម៉ាកុស ១៤៖១២-២៦; លូកា ២២៖៧-២៣)។ គម្ពីរដំណឹងល្អទាំងនេះ បានសរសេរពីយប់ដែលព្រះគ្រីស្ទត្រូវបានក្បត់ ទ្រង់យកនំប៉័ង ឲ្យពរ និងកាច់នំប៉័ង ហើយឲ្យទៅសិស្សដោយមានបន្ទូលថា «នេះជារូបកាយខ្ញុំ» បន្ទាប់ពីពិសារអាហាររួចហើយ ទ្រង់បានយកពែងស្រាទំពាំងបាយជូរ ឲ្យពរ ហើយឲ្យទៅពួកសិស្ស ដោយមានបន្ទូលថា «នេះជាឈាមនៃសញ្ញាថ្មី ដែលបានច្រួចចេញ សំរាប់មនុស្សជាច្រើនប្រយោជន៍នឹងផ្តាច់បាប» (ម៉ាថាយ ២៦៖២៦-២៨)

សាវក្យប៉ុល បាននិយាយពិធីលៀងព្រះអម្ចាស់ម្តងទៀតក្នុងព្រះគម្ពីរ ១កូរិនថូស១១៖២៣-២៦។ គាត់បានរំលឹកយើងពីប្រពៃណីរបស់ក្រុមជំនុំដែលគាត់ទទួលបានពីព្រះយេស៊ូវ ហើយឲ្យមកក្រុមជំនុំ និងយើងទាំងអស់គ្នា។

រឿងទាំងនេះដែលនិយាយពីព្រះបន្ទូលរបស់ព្រះគ្រីស្ទនៅក្នុងតុព្រះអម្ចាស់ ក្នុងបន្ទប់ខាងលើ គេថាការរៀបរាប់ជាស្ថាប័ន។ វានិយាយពីរបៀបដែលពិធីលៀងព្រះអម្ចាស់ចាប់ផ្តើម និងនិយាយពីការបញ្ជារបស់ព្រះយេស៊ូវ ដែលក្រុមជំនុំបន្តប្រារព្ធពិធីនេះ ជាការរំលឹកដល់ទ្រង់។[1]

[1] *This Holy Mystery: A United Methodist Understanding of Holy Communion* [hereafter THM] (Nashville: General Board of Discipleship, 2004), “The Meaning of Holy Communion,” 8-9.

រឿងទាំងនេះសង្កត់ធ្ងន់ទៅលើ សារៈសំខាន់នៃការដែលព្រះយេស៊ូវប្រទានរូបអង្គទ្រង់ សេចក្តី ស្មោះត្រង់របស់ទ្រង់ចំពោះព្រះអម្ចាស់ក្នុងការប្រឈមនិងសេចក្តីស្លាប់  និង ការដែលទ្រង់បន្ត យកចិត្តទុកដាក់ចំពោះសិស្សរបស់ទ្រង់។ បរិបទនៃអាហារបុណ្យរំលង រឿងដែលនិយាយពី អាហារចុងក្រោយ ផ្តោតលើទំនាក់ទំនងរវាងហេតុការ ដែលកើតឡើង ក្នុងពិធីបុណ្យរំលង (និក្ខមនំ ១២៖១-២៨) និងការសុគតរបស់ព្រះគ្រីស្ទលើឈើឆ្កាង។ រឿងក្នុងព្រះគម្ពីរ និក្ខមនំ ឈាមសត្វចៀមដែលសាសន៍អ៊ីស្រាអែលលាបលើគ្រោងទ្វារ គឺជាសញ្ញាដើម្បីកុំឲ្យព្រះ កាត់ទោសគ្រួសាររបស់គេ។ ក្នុងព្រះគម្ពីរដំណឹងល្អ រឿងអាហារ ចុងក្រោយ និងការឆ្កាង លោហិតរបស់ព្រះយេស៊ូវ ជាសញ្ញាដើម្បីកុំឲ្យព្រះ កាត់ទោស មនុស្សចំពោះអំពើបាបរបស់គេ។

មិនមែនមានតែរឿងទាំងនេះទេ ដែលជួយឲ្យយើងយល់ពីអត្ថន័យនៃពិធីលៀងព្រះអម្ចាស់ ។ រឿងផ្សេងទៀត ដូចជារឿងផ្តល់អាហារដល់ហ្វូងមនុស្ស (ម៉ាថាយ ១៤៖១៣-២១; ម៉ាកុស ៦៖៣០-៤៤ និង ៨៖១-១០; លូកា ៩៖១០-១៧; យ៉ូហាន ៦៖១-១៣, ២៥-៥៩) ក៏ទាក់ទងនិងរឿង អាហារក្នុងបន្ទប់ជាន់លើដែរ ព្រោះវាមាននិយាយពីការដែលព្រះយេស៊ូវ យកនំប៉័ង ឲ្យពរ កាច់ ហើយឲ្យដល់មនុស្ស។ ក្នុងរឿងទាំងនេះ យើងឃើញពីការដែល ព្រះយេស៊ូវ យកចិត្តទុក ដាក់ដល់មនុស្សដែលតាមទ្រង់។ រឿងទាំងនេះបង្ហាញថា ព្រះ ចម្អែតវិញ្ញាណពួកគេ ដោយសេចក្តីបង្រៀនរបស់ទ្រង់ និងចម្អែតរូបកាយរបស់ពួកគេ ដោយនំប៉័ង។

ក្នុងព្រះគម្ពីរយ៉ូហាន (យ៉ូហាន ៦៖២៥-៥១) រំលឹកក្រុមជំនុំថា នេះមិនមែនជាលើកដំបូង ក៏មិនមែនជាលើកចុងក្រោយដែរ ដែលព្រះអម្ចាស់ ផ្តល់អាហារដល់មនុស្ស ក្នុងវាល រហោស្ថាន។ យ៉ូហានរំលឹកយើងពីរឿងក្នុងព្រះគម្ពីរនិក្ខមនំ និងដំណើររបស់សាសន៍ អ៊ីស្រាអែល ក្នុង វាលខ្សាច់ (និក្ខមនំ ១៦៖១-១៧)។ ក្នុងវាលរហោស្ថាន ព្រះអម្ចាស់បាន ផ្គត់ផ្គង់សាសន៍អ៊ីស្រាអែលដោះនំម៉ាណា និងសត្វក្រួច ទោះបីជាសាសន៍អ៊ីស្រាអែលកំពុង សាកល្បងជា១ទ្រង់ក៏ដោយ (ទំនុកដំកើង ៩៥៖៩)។

រឿងផ្សេងទៀតដែលមានចែងពីការដែលព្រះយេស៊ូវទទួលនំប៉័ង ឲ្យពរ កាច់ ហើយឲ្យទៅ ហ្វូវមនុស្ស គឺកើតឡើងពេលព្រះយេស៊ូវជួបជាមួយពួកសិស្ស បន្ទាប់ពីទ្រង់រស់ពីសុគត។ ក្នុងព្រះគម្ពីរលូកា ២៤៖១៣-៣៥ ព្រះយេស៊ូវជួបជាមួយសិស្សពីរនាក់ តាមផ្លូវទៅស្រុក អេម៉ុស។ ទោះបីជាពួកគេមិនស្គាល់ទ្រង់ពេលគេកំពុងធ្វើដំណើរ ពួកគេបានឃាងទ្រងឲ្យ នៅបរិភោគជាមួយពួកគេ។ បន្ទាប់ពីព្រះយេស៊ូវទទួលនំប៉័ង ឲ្យពរ កាច់ ហើយឲ្យទៅ ពួកគេបរិភោគ ភ្នែករបស់ពួកគេបានបើកឡើង ហើយពួកគេស្គាល់ទ្រង់។ ស្រដៀងគ្នានេះ ដែរ យ៉ូហានបានសរសេថា ពេលព្រះយេស៊ូវមកជួបពួកសិស្សនៅលើឆ្នេរ ទ្រង់បានរៀបចំ អាហារឲ្យពួកគេ ហើយគេបានស្គាល់ទ្រង់ (យ៉ូហាន ២១៖៤-១៤)។

ក្នុងគម្ពីរកិច្ចការ ២៖៤២-៤៧ យើងអានពីក្រុមជំនុំដំបូងដែលចងចាំពីព្រះយេស៊ូវ តាមរយៈការបង្រៀនរបស់សាវក្ស ក្នុងការប្រកបជាសហគមន៍ កាច់នំប៉័ង និងការអធិស្ឋានរួមគ្នា។ សកម្មភាពទាំងនេះ ក្លាយជាកំណត់សំគាល់យ៉ាងសំខាន់ សំរាប់សហគមន៍គ្រីស្ទបរិសទ្ធដើម។

ក្នុងរឿងនិមួយៗ យើងឃើញពីវត្តមាន និងការយកចិត្តទុកដាក់របស់ព្រះគ្រីស្ទ ដល់សហគមន៍នៃសេចក្ដីជំនឿ។ ក្នុងរឿងអាហារចុងក្រោយក្នុងគម្ពីរម៉ាថាយ ម៉ាកុស និងលូកា ព្រះយេស៊ូវ ជំនួសកន្លែងកូនចៀមសំរាប់បូជា (រឿងថ្ងៃរំលង) សំរាប់ជំនួសបាបយើង។ យើងនឹកចាំពីរឿង ក្នុងគម្ពីរនិក្ខមនំ ក្នុងការបង្រៀនរបស់ព្រះយេស៊ូវអំពីនំប៉័ងជីវិត។ សកម្មភាពរបស់ព្រះគ្រីស្ទ ទាក់ទងគ្នានិងការយកចិត្តទុកដាក់របស់ព្រះគ្រីស្ទ សំរាប់សហគមន៍នៃសេចក្ដីសញ្ញារបស់ ទ្រង់ ដោយការប្រទានអាហារក្នុងវាលរហោស្ថាន។ ក្នុងការផ្ដល់អាហារដល់ហ្វូងមនុស្ស ការចែកចាយអាហារ គឺជាសញ្ញាមួយនៃសេចក្ដីមេត្តាករុណារបស់ទ្រង់ ដល់អ្នកដែលដើរតាមទ្រង់ និងស្ដាប់សេចក្ដីបង្រៀនរបស់ទ្រង់។ បន្ទាប់ពីទ្រង់រស់ពីសុគតឡើងវិញ ព្រះយេស៊ូវបន្ត បង្ហាញវត្តមានរបស់ទ្រង់ដល់ពួកសិស្ស និងសហគមន៍នៃសេចក្ដីជំនឿដោយការយកចិត្តទុកដាក់។ ក្នុងជីវិតក្រុមជំនុំដើម ដែលមានសរសេរទុកក្នុងគម្ពីរកិច្ចការ ក្រុមជំនុំនឹកចាំពីការប្រជុំគ្នារាល់សប្ដាហ៍ ដែលមានដង្វាយ ការប្រកបគ្នា និងការថែរក្សាគ្នា ដែលព្រះយេស៊ូវបានប្រទានឲ្យ ដូចកាលដែលទ្រង់នៅជាមួយរាស្ត្ររបស់ទ្រង់ក្នុងគ្រប់កាលៈទេសៈក្នុងជីវិត និងបាន ចូលរួមអាហារជាមួយគេ។

# ឈ្មោះ សំរាប់ពិធីលៀងព្រះអម្ចាស់

និកាយផ្សេងគ្នា ហៅពិធីលៀងព្រះអម្ចាស់ផ្សេងគ្នា៖ Eucharist, Lord's Supper, Holy Communion។ ទោះជាមានឈ្មោះច្រើនទៀតសំរាប់ពិធីនេះ តែឈ្មោះទាំងបីនេះត្រូវបានប្រើច្រើនជាងគេ ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ។ ឈ្មោះនិមួយៗ មានឫសគល់ក្នុងគម្ពីរសញ្ញាថ្មី និងជីវិតក្រុមជំនុំដំបូង។



និកាយខ្លះរាប់ពិធីនេះជាពិធីវិសុទ្ធ ចំណែកនិកាយខ្លះទៀតហៅពិធីនេះជា បញ្ញាតិ (Ordinance)[2]។ ជាយូណៃធីតមេថូឌីស្ទ យើងយល់ថាពិធីលៀងព្រះអម្ចាស់ជាពិធីវិសុទ្ធ ។ ពិធី លៀងព្រះអម្ចាស់ (និងពិធីជ្រមុជទឹក) គឺជាវិធីដែលព្រះអម្ចាស់មកជួបយើង ធ្វើការក្នុងយើង និងផ្តល់ឲ្យយើងនូវសេចក្តីមេត្តា និងសេចក្តីស្រឡាញ់។ ពិធីវិសុទ្ធ គឺជា «សញ្ញានៃព្រះគុណ និងគោលបំណងល្អរបស់ព្រះអម្ចាស់សំរាប់យើង»។ ក្នុងពិធីវិសុទ្ធ «ព្រះអម្ចាស់ធ្វើការក្នុងយើង ដោយពន្លឿន ពង្រឹង និងបញ្ជាក់សេចក្តីជំនឿរបស់យើង។»[3]

ពាក្យថា sacrament ក្លាយមកពីភាសាឡាតាំង ដែលមានន័យថា ពាក្យសន្យា ឬពាក្យសម្បត់ ។ ក្នុងករណីនេះ វាគឺជាសេចក្តីសន្យាព្រះ សំរាប់វត្តមានទ្រង់ក្នុងជីវិតយើង។ កិច្ចសន្យានៃពិធីលៀងព្រះអម្ចាស់ គឺជាសញ្ញានៃការសន្យាមកពីព្រះចំពោះក្រុមជំនុំ និងជាសញ្ញានៃភាពអាថ៌កំបាំងនៃសេចក្តីស្រឡាញ់ សំរាប់ព្រះសំរាប់ពិភពលោក។[4]

ផ្ទុយមកវិញ បញ្ញាតិ គឺជាកាបញ្ជា ឬជាច្បាប់។ ពេលយើងគិតថាអាហារបរិសុទ្ធ ជាបញ្ញាតិ

---

[2] *THM*, "Names of the Sacrament," 3-4.

[3] សៀវភៅវិន័យយូណៃធីតមេថូឌីស្ទឆ្នាំ 2012 (Nashville: United Methodist Publishing House, 2012), ¶104, pages 67 and 72.

[4] *THM*, "The theology of sacraments," 7.

យើងនិយាយថា យើងចូលរួមក្នុងអាហារបរិសុទ្ធនេះ ដើម្បីបំពេញបទបញ្ជារបស់ព្រះយេស៊ូវ ដែល យើង «ធ្វើនេះ» ទុកជាការរំលឹកដល់ទ្រង់។

ការយល់ពីអាហារបរិសុទ្ធ ជាពិធីវិសុទ្ធ បញ្ជាក់ពីសកម្មភាពរបស់ព្រះ ក្នុង និងតាមរយៈអាហារនេះ។ ការយល់ដូចនេះ បញ្ជាក់ពីវិធី ដែលសេចក្តីស្រឡាញ់របស់ព្រះមកដល់យើងទាំងអស់គ្នា ដោយសារអំណោយទាននៃព្រះគុណ។ ការយល់ថាអាហារបរិសុទ្ធជាបញ្ញាតិធ្វើឲ្យយើងផ្តោតទៅលើការគោរព និងសកម្មភាពក្នុងអាហារនេះ។ ការយល់យ៉ាងនេះបញ្ជាក់ពីតួនាទី ដែលយើងត្រូវតែឆ្លើយតបចំពោះវត្តមាននៃព្រះគុណរបស់ព្រះ ដែលទាមទារឲ្យយើងធ្វើតាម។[5] ជាយុំណៃធីតមេថូឌីស្ទ យើងផ្តល់អទិភាពទៅលើកិច្ចការព្រះគុណរបស់ព្រះ ក្នុងជីវិតរបស់យើង ដែលមានន័យថាយើងក៏ផ្តល់អទិភាពទៅលើសេចក្តីសន្យានៃអាហារវិសុទ្ធនេះដែរ។ ការគោរពតាម និងសកម្មភាពរបស់យើង តែងតែឆ្លើយតបនិងសកម្មភាពរបស់ព្រះ ក្នុងជីវិតរបស់យើង។

ពាក្យថា Eucharist មកពីភាសាក្រិក ដែលមានន័យថា អរព្រះគុណ។[6] ក្នុងរឿងអាហារនៅបន្ទប់ខាងលើ និងក្នុងរឿងអោយអាហារដល់ហ្វូងមនុស្ស សកម្មភាពរបស់ព្រះយេស៊ូវត្រូវបានពិពណ៌នាថា យក ឲ្យពរ ឬអរព្រះគុណ កាច់ និងឲ្យ។ ក្នុងម៉ាថាយ ២៦៖២៥-២៧ និង ម៉ាកុស ១៤៖២២-២៣ ព្រះយេស៊ូវឲ្យពរដល់នំប៉័ង និងអរព្រះគុណសំរាប់ពែង។ ការហៅអាហារមួយពេលនេះថា Eucharist ជួយឲ្យយើងចាំថា ពេលដែលកាច់នំប៉័ង និងឲ្យទឹកទំពាំងបាយជូរ ព្រះយេស៊ូវអរព្រះគុណដល់ព្រះ សំរាប់ការសង្គ្រោះរបស់ទ្រង់ក្នុងពិភពលោក។ វាក៏សង្កត់ន័យទៅលើការសរសើរដំកើង និងការអរព្រះគុណ ដែលយើងឲ្យទៅព្រះ ក្នុងការអធិស្ឋានរបស់យើង នៅពិធីលៀងព្រះអម្ចាស់ និងការដែលយើងបរិភោគចំណិតនំប៉័ង និងទឹកទំពាំងបាយជូរ។

ពេលយើងប្រើពាក្យ Lord's Supper យើងប្រើតាមការពិពណ៌នារបស់សាវក្យប៉ុលក្នុង ១កូរិនថូស១១។[7] ក្នុងបទគម្ពីរនេះ សាវក្យប៉ុល បាននិយាយពីការដែលក្រុមជំនុំប្រព្រឹត្តខុសចំពោះអាហារនេះ។ ក្រុមជំនុំក្នុងទីក្រុងកូរិនថូស មានការបែកបាក់ និងការមិនស្មើរភាពរវាងសមាជិក និងសហគមន៍។ អ្នកខ្លះមកមុន ហើយបរិភោគ និងផឹក ច្រើនដែលធ្វើឲ្យអ្នកមកដល់ក្រោយអត់ឃ្លាន (១កូរិនថូស១១៖១៧-២២)។ សំរាប់សាវក្យប៉ុល សកម្មភាពបែបនេះក្បត់គោលបំណងនៃពិធីលៀងព្រះអម្ចាស់ ដែលជាសកម្មភាពនៃរូបកាយទាំងមូលរបស់ព្រះគ្រីស្ទ ដែលជាក្រុមជំនុំ។

---

[5] ចំនុចនេះគឺជាខ្លឹមសារនៃសេចក្តីអធិប្បាយរបស់លោកចន វេស្លី "The Duty of Constant Communion."

[6] *THM*, "Names of the Sacrament," 4.

[4] *THM,* "Names of the Sacrament," 3.

វាងាយនិងជឿណាស់ថាអាហារវិសុទ្ធនេះជារបស់ក្រុមជំនុំ។ ប៉ុន្តែសាវក្យប៉ុលបានព្រមាន ក្រុមជំនុំកូរិនថូសថា វាមិនមែនជាអាហារវិសុទ្ធរបស់យើង ដែលយើងអញ្ជើញអ្នកផ្សេងឲ្យ ចូលរួមនោះទេ តែវាជាអាហាររបស់ព្រះគ្រីស្ទ ដែលយើងត្រូវបានអញ្ជើញ។ ដែល មានន័យថា យើងមិនមែនជាម្ចាស់កម្មវិធីទេ គឺព្រះគ្រីស្ទវិញជាម្ចាស់កម្មវិធី។ ទ្រង់អញ្ជើញ យើងមក កាន់អាហារពេលល្ងាចរបស់ទ្រង់ ដែលយើងអាចចូលរួមជាមួយទ្រង់ និងជាមួយ អ្នកដទៃជុំវិញតុរបស់ទ្រង់។

ឈ្មោះទីបីដែលគេឧស្សាហ៍ប្រើ គឺ Holy Communion.[8] ឈ្មោះនេះបង្ហាញពីការដែល យើង ប្រជុំគ្នាជុំវិញតុរបស់ព្រះអម្ចាស់ យើងធ្វើការទំនាក់ទំនងជាមួយព្រះគ្រីស្ទ និងជាមួយ អ្នកដទៃ។ ពេលដែលសាវក្យប៉ុលប្រដៅក្រុមជំនុំនៅទីក្រុងកូរិនថូស គាត់បាននិយាយពី ការបរាជ័យរបស់ពួកគេ ដើម្បីឲ្យដឹងពីការទំនាក់ទំនងជាមួយព្រះ ដែលទាមទារឲ្យយើង មាន ទំនាក់ទំនងជាមួយអ្នកដទៃ។ ក្រុមជំនុំកូរិនថូសមិនយល់ពីរូបកាយនៃព្រះគ្រីស្ទ ដែល មានវត្តមាននៅក្នុងសហគមន៍នៃសេចក្តីជំនឿដែលកំពុងប្រជុំគ្នាជុំវិញតុព្រះអម្ចាស់។ តាមរយៈការបរិភោគនំប៉័ងនិងទឹកទំពាំងបាយជូរ ជាមួយគ្នាក្នុងសហគមន៍នៃសេចក្តីជំនឿ យើងមានទំនាក់ទំនងជាមួយព្រះអម្ចាស់ ក្នុងព្រះគ្រីស្ទយេស៊ូវ ក៏ដូចជាចូលទៅក្នុង ទំនាក់ទំនងនៃសេចក្តីស្រឡាញ់ជាមួយអ្នកដទៃ។ ក្នុងពិធីលៀងព្រះអម្ចាស់ ការ អរព្រះគុណដល់ព្រះ និងការចូលរួមបរិភោគជាមួយព្រះអម្ចាស់ ក្លាយទៅជាវិធីមួយដែល យើងអាចបំពេញបញ្ញាតិ ទាំងពីររបស់ព្រះអម្ចាស់ក្នុងការស្រឡាញ់ព្រះ និងអ្នកជិតខាង។

---

[8] *THM*, "Names of the Sacrament," 4.

# ព្រះបន្ទូល និងតុព្រះអម្ចាស់

គម្រោងនៃកម្មវិធីលៀងព្រះអម្ចាស់ មានក្នុងកម្មវិធី ព្រះបន្ទូល និងតុព្រះអម្ចាស់។[9] ទម្រង់គ្រឹះនៃកម្មវិធីនេះអាចឃើញក្នុងរឿង ទីក្រុងអេម៉ុស ក្នុងគម្ពីរកិច្ចការ ២៤៖១៣-៣៥។[10] ដំណើរទៅកាន់ទីក្រុងអេម៉ុស ព្រះគ្រីស្ទរួមដំណើរជាមួយពួកសិស្ស។ ព្រះយេស៊ូវបកស្រាយព្រះគម្ពីរឲ្យគេ ហើយបរិភោគជាមួយគេ។ ក្នុងការយក ឲ្យពរ ឬអរព្រះគុណ កាច់ និងឲ្យ នំប៉័ងនេះហើយ ដែលភ្នែករបស់ពួកសិស្សបានបើក ហើយស្គាល់ព្រះគ្រីស្ទ។ ពួកសិស្សត្រឡប់ទៅក្រុងយេរូសាឡឹម ប្រកាសដំណឹងល្អនៃការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

គំរូចម្បង នៃការប្រកាស និងការឆ្លើយតប (ព្រះបន្ទូល) និងការអរព្រះគុណ និងការប្រកប (តុព្រះអម្ចាស់) បង្កើតឲ្យមានជាគម្រូវនៃការថ្វាយបង្គំរបស់យូណៃធីតមេថូឌីស្ទសព្វថ្ងៃនេះ។[11] វាមានព្រះបន្ទូល ដែលចែងក្នុងបទគម្ពីរ និងការអធិប្បាយ ដូចក្នុងព្រះបន្ទូល និងតុព្រះអម្ចាស់ដែរ។ វាក៏មានព្រះបន្ទូលនៅលើតុព្រះអម្ចាស់ពេលដែលកាច់នំប៉័ង និងចែកទឹកទំពាំងបាយជូរ ដែលមានក្នុងការអាន និងការអធិប្បាយ។ យើងមិនអាចធ្វើដោយគ្មានការណាមួយបាននោះទេ។ គំរូនេះក៏ផ្តល់ឲ្យក្រុមជំនុំនូវគ្រឹះនៃសាមគ្គីភាពក្នុងការថ្វាយបង្គំ ទោះបីវាបង្ហាញ ពីភាពខុសផ្លែកពីគ្នានៃការអនុវត្ត ក្នុងក្រុមជំនុំផ្សេងៗគ្នា។

ក្នុងគំរូគ្រឹះនៃ ព្រះបន្ទូល និងតុព្រះអម្ចាស់នេះ គម្រូវនៃកម្មវិធីនៃតុព្រះអម្ចាស់ បង្ហាញពីរាងទាំងបួនដែលយើងឃើញក្នុងរឿងអាហាររបស់ព្រះយេស៊ូវជាមួយពួកសិស្ស។ ទីមួយ ព្រះយេស៊ូវយកនំប៉័ង និងពែង។ ទីពីរ ទ្រង់ឲ្យពរ ឬអរព្រះគុណដល់ព្រះ។ ទីបី ទ្រង់កាច់នំប៉័ង និងចាក់ទឹកទំពាំងបាយជូរ និងទីបួន ទ្រង់ឲ្យនំប៉័ង និងពែង ទៅពួកសិស្សទ្រង់។

អស់រាប់សតវត្សមកហើយដែលក្រុមជំនុំយល់ថា បញ្ញាតិរបស់ព្រះយេស៊ូវឲ្យ «ធ្វើការនេះ» ដើម្បីបញ្ចូលមិនត្រឹមតែការកាច់និងឲ្យនំប៉័ងនិងពែងប៉ុណ្ណោះទេ តែក៏បញ្ចូលទាំងការទទួល និងការឲ្យពរ ឬអរព្រះគុណដល់ព្រះ សំរាប់អ្វីដែលក្រុមជំនុំបានទទួល និងបន្តទទួលពីព្រះ ក្នុងការបង្កើត ការលោះបាប និងការញែកជាបរិសុទ្ធ។

---

[9] សៀវភៅចំរៀងមេថូឌីស្ទ (Nashville: United Methodist Publishing House, 1989), 6–31. See *THM* “The basic pattern of worship” 18-20 and “The ritual of the church,” 23-25.

[10] *THM*, “Background,” 4.

[11] *THM*, “The basic pattern of worship,” 18.

ក្នុងការទទួល និងការឲ្យពរ (ការអរព្រះគុណ) យើងរៀបតុ និងខ្លួនយើង ដើម្បីទទួលអំណោយដែលព្រះប្រទាន មកយើង ក្នុងព្រះយេស៊ូវគ្រីស្ទ។ ម្យ៉ាង នេះជាការៀបចំតុដូច ដែលយើងរៀបចំតុបាយយើងដែរ។ ម្យ៉ាងទៀត ការរៀបចំនេះ ទាក់ទងនិងការរៀបចំចិត្តគំនិតរបស់យើង ដើម្បីឲ្យយើងដឹងថាព្រះគ្រីស្ទមានវត្តមានជាមួយយើង ក្នុងការដែលយើង ទទួលនំប៉័ងនិងពែង ជាមួយអ្នកដទៃ។




ក្នុងការកាច់និងការឲ្យ (ការប្រកប) យើងប្រឈមជាមួយការអនុវត្តនៃការកាច់នំប៉័ង ដើម្បីចែកចាយជាមួយអ្នកដទៃ។ យើងនឹកចាំថា ពេលដែលព្រះយេស៊ូវកាច់នំប៉័ង ដែលមានន័យដូចជា ការកាច់រូបកាយទ្រង់សម្រាប់ពិភពលោក ព្រះយេស៊ូវ បន្តប្រទានរូបកាយបែកបាក់នេះដល់យើង  សំរាប់ប្រោសយើង និងប្រោសពិភពលោកឲ្យបានជា។

ក្នុងការអរព្រះគុណ និងការប្រកប យើងចូលរួមជាមួយការងារនៃការរៀបចំតុ និងធ្វើឲ្យអ្នកដទៃអាចចូលរួមទទួលអាហារនេះបានដែរ។ យើងក៏ចូលរួមជាមួយការងារផ្នែកទេវសាស្រ្ត ក្នុងការអរព្រះគុណ ដែលរំលឹកយើងពីអ្វីដែលព្រះបន្តធ្វើជាមួយយើង និងសម្រាប់យើង។ ការងារទេវសាស្រ្តនេះ នាំទៅកាន់ការប្រកបជាមួយព្រះ និងជាមួយអ្នកដទៃ ដែលព្រះហៅយើងឲ្យចែករំលែកអាហារប្រចាំថ្ងៃដល់អ្នកដែលត្រូវការបំផុត។

# ការអរព្រះគុណ

សេចក្តីអធិស្ឋានអរព្រះគុណក្នុងកម្មវិធី ពាក្យពេជ្យនិងតុ ត្រូវបានហៅឈ្មោះថា ការអរព្រះគុណ ឬសេចក្តីអធិស្ឋាន Eucharist.[12]

ការអរព្រះគុណ បង្ហាញពីការយល់អំពីព្រះត្រ័យឯក។ សេចក្តីអធិស្ឋានទាំងមូល គឺជាការអរព្រះគុណ ចំពោះព្រះវបិតា។ ការអរព្រះគុណនេះក៏មានបញ្ចូលការនឹកចាំពីអ្វីដែលព្រះបានធ្វើក្នុងព្រះយេស៊ូវគ្រីស្ទ និងការទូលដល់ព្រះវិញ្ញាណបរិសុទ្ធ ចំពោះអំណោយទានទាំងពីរ គឺនំបុ័ង និងទឹកទំពាំងបាយជូ និងសហគមន៍ទាំងមូលប្រមូលផ្តុំគ្នាជុំវិញតុព្រះអម្ចាស់។[13]

ទម្រង់ព្រះត្រ័យឯកនេះផ្តល់ឲ្យក្រុមជំនុំនូវឱកាសសំរាប់អរព្រះគុណ ដើម្បីនឹកចាំពីព្រះយេស៊ូវគ្រីស្ទ និងទូលអង្វរដល់ព្រះវិញ្ញាណបរិសុទ្ធ។ វាជាសំឡេងនៃការប្រកបជាមួយព្រះគ្រីស្ទ ជាមួយអ្នកជិតខាង និងជាមួយពិភពលោក។ វាក៏រំលឹកយើងដែរថា អាហារដ៏បរិសុទ្ធនេះ គឺជារស់ជាតិដែលយើងនឹងទទួល ពេលយើងចូលរួមក្នុងពិធីជប់លៀងរបស់ព្រះគ្រីស្ទនៅនគរថានសួគ៌។

គម្រោងនៃកម្មវិធីអរព្រះគុណមាន៥ផ្នែក[14]៖

១ ការចាប់ផ្តើមសន្ទនា

២ ការអរព្រះគុណដល់ព្រះ

៣ ការនឹកចាំពីព្រះយេស៊ូវគ្រីស្ទ

៤ ការទូលអង្វរដល់ព្រះវិញ្ញាណបរិសុទ្ធ

៥ ការសរសើរដំកើងបញ្ចប់

---

[12] See *The United Methodist Hymnal*, 9–10 and *THM*, “The Prayer of Great Thanksgiving,” 20-22.

[13] *THM*, “The Prayer of Great Thanksgiving,” 21.

[14] *THM*, “The Prayer of Great Thanksgiving,” 21.

# ការចាប់ផ្ដើមសន្ទនា

កម្មវិធីអរព្រះគុណចាប់ផ្ដើមដោយការចាប់ផ្ដើមសន្ទនា រវាងគ្រូគង្វាល និងក្រុមជំនុំ៖

ព្រះអម្ចាស់គង់នៅជាមួយអ្នក

ទ្រង់ក៏គង់នៅជាមួយអ្នកដែរ

សូមបើកចិត្តលោកអ្នក

យើងទាំងអស់គ្នាសូមបើកដួងចិត្តសំរាប់ព្រះអម្ចាស់

សូមយើងអរព្រះគុណដល់ព្រះអម្ចាស់ជាព្រះនៃយើង

នេះជាការត្រឹមត្រូវដែលយើងអរព្រះគុណ និងសរសើរព្រះអង្គ[15]

ការសន្ទនានេះមានអត្ថប្រយោជន៍មួយចំនួន។ វាចាប់ផ្ដើមដោយការស្វាគមន៍រវាង គ្រូគង្វាល និងក្រុមជំនុំ ដែលយើងយាងព្រះអម្ចាស់មកគង់ជាមួយយើង ហើយប្រទានពរ ដល់យើងក្នុងពេលដែលយើងជុំគ្នាក្នុងតុព្រះអម្ចាស់។ ការឆ្លងឆ្លើយបន្ទាប់បង្គាប់ឲ្យយើង រៀបចំចិត្តរបស់យើង។ យើងថ្វាយចិត្ត និងគំនិតរបស់យើង សំរាប់ផ្ដោតទៅលើសេចក្ដី ស្រឡាញ់របស់ព្រះ។ ការសន្ទនាចុងក្រោយសំខាន់ណាស់ ព្រោះវារំលឹកថា ការអរព្រះគុណ ដែលគ្រូគង្វាលបានធ្វើ មិនជារបស់គាត់តែម្នាក់ទេ ប៉ុន្តែក្រុមជំនុំទាំងមូលជាអ្នកធ្វើ។

# ការអរព្រះគុណ

ផ្នែកទីពីរនៃការអធិស្ឋាននេះ គឺជាការអរព្រះគុណចំពោះព្រះវបិតា។ ត្រង់នេះយើងនឹកចាំពី សេចក្ដីសង្គ្រោះរបស់ព្រះក្នុងប្រវត្តិសាស្ត្រ។ ជាពិសេសយើងចាំពីការបង្កើតរបស់ព្រះ សេចក្ដីសញ្ញារបស់ និងសេចក្ដីស្រឡាញ់មិនចេះប្រួលប្រែរបស់ទ្រង់ ក្នុងពេលដែលមនុស្ស មិនស្មោះត្រង់ ទាំងការរំដោះចេញពីទាសភាព និងការថែរក្សាររបស់ព្រះតាមរយៈព្រះបន្ទូល និងពួកហោរា។ ផ្នែកនេះបញ្ចប់ដោយក្រុមជំនុំច្រៀងឆ្លើយតប «បរិសុទ្ធ បរិសុទ្ធ ព្រះអម្ចាស់ បរិសុទ្ធ ព្រះអម្ចាស់ដ៏មានអំណាច និងព្រះចេស្តា...» បទចម្រៀងសរសើរខ្លីមួយនេះ គឺជា បទសរសើររបស់ទេវតានៃព្រះជុំវិញបល្ល័ង្ករបស់ព្រះ ដែលមានចែងក្នុងគម្ពីរអេសាយ ជំពូក៦ ។ វាក៏ដូចជាការស្វាគមន៍ចំពោះដំណើរយាងចូលមក ក្នុងទំនុកដំកើង១១៨៖២៦ ដែល ហ្វូងមនុស្សស្វាគមន៍ព្រះយេស៊ូវចូលក្រុងយេរូសាឡឹម (ម៉ាថាយ ២១៖៩; ម៉ាកុស ១១៖៩) ។ ចំរៀងសរសើររបស់យើងចូលរួមជាមួយពួកទេវតា និងហ្វូងមនុស្សទាំងនោះ។

[15] "A Service of Word and Table I" in *The United Methodist Hymnal*, 9.

# ការនឹកចាំ

វគ្គទីបីនៃសេចក្ដីអធិស្ឋានបែរការផ្ដោតអារម្មណ៍របស់យើងចំពោះការងារ និងពន្ធកិច្ចរបស់ព្រះយេស៊ូវ និងមានទាំងការពិពណ៌នា។[16] ក្នុងវគ្គនេះ ក្រុមជំនុំនឹកចាំពីដំណឹងល្អនៃការរំដោះ សេរីភាព និងការប្រោសឲ្យជា ដែលព្រះយេស៊ូវអធិប្បាយ។ (សេចក្ដីអធិស្ឋាននេះមានក្នុងគម្ពីរអេសាយ ៦១៖១ និង លូកា ៤៖១៨-១៩)។ យើងចាំថា ក្នុងការឈឺចាប់ សុគត និងរស់ឡើងវិញរបស់ព្រះយេស៊ូវ យើងបានរំដោះពីទាសភាពចំពោះអំពើបាប និងសេចក្ដីស្លាប់ ហើយទទួលបានសេរីភាពសំរាប់ជីវិតក្នុងព្រះអម្ចាស់។ គោលគំនិតនេះបង្ហាញពីការតាំងចិត្តប្រវត្តិសាស្ត្រ ចំពោះបេសកកម្មក្នុងពិភពលោក។[17] ផ្នែកនេះជាទូទៅត្រូវបានរៀបរាងឡើងសំរាប់បង្ហាញគោលគំនិតមួយចំនួនដែលទាក់ទងនិងរដូវកាលក្រុមជំនុំ ដូចជាកំណើតព្រះយេស៊ូវ ក្នុងស្នូកសត្វ ឬ៤០ថ្ងៃក្នុងវាលរហោស្ថាន។ ការចង់ចាំកិច្ចការអស្ចារ្យរបស់ព្រះ ក្នុងព្រះគ្រីស្ទ យេស៊ូវ និងដង្វាយរបស់ព្រះគ្រីស្ទសំរាប់យើង ហើយយើងចូលរួមក្នុងព្រះគ្រីស្ទ និងផ្ដល់ខ្លួនយើងក្នុងការសរសើរដំកើង និងការអរព្រះគុណ។ ផ្នែកនេះបញ្ចប់ដោយការប្រកាសរួមរបស់ ក្រុមជំនុំ ឬចំរៀងសរសើរ ដែលយើងប្រកាសសេចក្ដីជំនឿរបស់យើង និងសេចក្ដីសង្ឃឹមជាគ្រីស្ទបរិសទ្ធ «ព្រះគ្រីស្ទបានសុគត ព្រះគ្រីស្ទបានរស់ឡើងវិញ ព្រះគ្រីស្ទនឹងយាងមកវិញម្ដងទៀត»

# ការអំពាវនាវ

ផ្នែកទីបួននៃសេចក្ដីអធិស្ឋាន អញ្ជើញវត្តមាន និងអំណាចព្រះវិញ្ញាណបរិសុទ្ធ មកចំពោះចំណិតនំប៉័ងនិងពែង និងសំរាប់សហគមន៍ដែលកំពុងនៅជុំវិញតុព្រះអម្ចាស់។ ក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ចំណិតនំប៉័ង និងទឹកទំពាំងបាយជូរ ក្លាយជារូបកាយ និងលោហិតព្រះគ្រីស្ទ ដូចដែលយើងក្លាយជារូបកាយរបស់ព្រះគ្រីស្ទសំរាប់ពិភពលោក។[18] ចូលរួមជាមួយព្រះគ្រីស្ទ និងជាមួយគ្នាក្នុងសេចក្ដីស្រឡាញ់ និងអំណាចរបស់ព្រះអម្ចាស់ យើងត្រូវបានផ្ដល់ឲ្យនូវភារៈកិច្ចក្នុងការនាំដំណឹងល្អនៃសេចក្ដីស្រឡាញ់របស់ព្រះទៅកាន់ពិភពលោក។

---

[16] សូមមើលទំព័រទី៨ខាងលើ។ Also see *THM*, "The Meaning of Holy Communion," 8.

[17] *THM*, "Holy Communion and Ethical Discipleship," 35.

[18] *THM*, "The Meaning of Holy Communion," 9.

# ចំរៀងសរសើរ

ផ្នែកទីប្រាំ ដែលជាផ្នែកបញ្ចប់ បញ្ចប់ដោយការច្រៀងសរសើរ បញ្ចប់ដោយការអរព្រះគុណ ដូចកាលចាប់ផ្តើម។ សេចក្តីអធិស្ឋាន បញ្ចប់ដោយការសរសើរ និងការអរព្រះគុណចំពោះ ព្រះត្រៃឯក៖ ព្រះវបិតា ព្រះរាជ្យបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ យើងបញ្ចប់ការអធិស្ឋាន ដោយផ្តល់ព្រះកិត្តិយស សិរីរុងរឿង និងការសរសើរដល់ព្រះអម្ចាស់។ ក្រុមជំនុំឆ្លើយតបចំពោះការទាំងអស់នេះដោយពាក្យថា «អាម៉ែន»។ នេះបញ្ជាក់ថា ការទាំងអស់នេះត្រូវបាន អធិស្ឋានដោយឈ្មោះយើងផ្ទាល់។ ពាក្យថា «អាម៉ែន» គឺជាពាក្យមួយដែលមានន័យថា «បាទ/ចាស សំរាប់សេចក្តីអធិស្ឋាននេះ។»[19]

## សំនួរអំពីការអធិស្ឋាន
## អរព្រះគុណ

**សំ៖** កម្មវិធីយើងមិនមានពេលគ្រប់គ្រាន់សំរាប់ធ្វើតាមពិធីការទាំងមូលនៃពិធីលៀងព្រះអម្ចាស់ទេ។ តើមានពិធីអរព្រះគុណណាដែលខ្លី ជាងនេះទេ?

**ចំ៖** ភាគច្រើន យើងជាគ្រូគង្វាល តែងតែមានសម្ពាធចង់ធ្វើអ្វីឲ្យឆាប់ ហើយមានប្រសិទ្ធភាព។ តែការដែលយើងរស់នៅក្នុងអាចកំបាំងនេះ ពេលវេលាមិនគួរណាមានសារៈសំខាន់ជាងពិធីលៀងព្រះអម្ចាស់ទេ។[20] កម្មវិធីព្រះបន្ទូល និងតុព្រះអម្ចាស់III មិនមែនជា «ពិធីខ្លី»។ (សូមចំណាំថា កម្មវិធីព្រះបន្ទូល និងតុព្រះអម្ចាស់III មិនមែនជា «ពិធីខ្លី» តែវាផ្តល់ជាគម្រោងសំរាប់សេចក្តីអធិស្ឋានដោយមានពាក្យជំនួយ សំរាប់ក្រុមជំនុំឆ្លើយតប។) សេចក្តីអធិស្ឋាននេះខ្លី ប៉ុន្តែវានៅតែមាន «ការសន្ទនា, ការអរគុណចំពោះកិច្ចការអស្ចារ្យ របស់ព្រះ និងសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ, ការប្រារព្ធពិធីអាហារព្រះអម្ចាស់, ការប្រកាសពីកិច្ចការរបស់ព្រះវិញ្ញាណ, និងបញ្ចប់ដោយការសរសើរ ព្រះត្រៃឯក។»[21] ប៉ុន្តែ ក្នុងសៀវភៅ *The Worship Resources of The United Methodist Hymnal* លោក Hoyt Hickman បានសរសេរថា គ្រូគង្វាលដែលជ្រើសរើសប្រើកម្មវិធី ព្រះបន្ទូល និងតុព្រះអម្ចាស់III គួរ «ពិចារណាដោយប្រុងប្រយត្ន័ ហើយ

[19] *THM*, “The Whole Assembly,” 20.

[20] *Living into the Mystery*, 8.

[21] *THM*, “The Prayer of Great Thanksgiving,” 21.

រៀបចំមាតិការនៃកម្មវិធីអរព្រះគុណ» ដូចដែលមាន «រៀបរាប់ពីការយល់របស់ក្រុមជំនុំពីកិច្ចការអស្ចារ្យរបស់ព្រះក្នុងព្រះគ្រីស្ទយេស៊ូវ និងអត្ថន័យនៃពិធីលៀងព្រះអម្ចាស់។»[22] ចុងក្រោយ «លោកអភិបាល គ្រូគង្វាល និងក្រុមជំនុំត្រូវប្រើកម្មវិធី ព្រះបន្ទូល និងតុព្រះអម្ចាស់ ក្នុងសៀវភៅចំរៀងយូណៃធីតមេថូឌីស្ទ និងសៀវភៅថ្វាយបង្គំ។ ការប្រើសៀវភៅទាំងនេះដោយការយល់ដឹង ធ្វើឲ្យយើងអាចបំពេញសេចក្តីត្រូវការតាមបរិបទ និងលំដាប់លំដោយ ដែលបង្ហាញពីសាមគ្គីភាពរបស់យើង និងការជួយគ្នាទៅវិញទៅមក។»[23]

**សំ៖** តើពេលណាដែលគ្រូគង្វាលកាច់នំប៉័ង? នៅពេលដែលព្រះយេស៊ូវមានបន្ទូលពីនំប៉័ង ឬពេលក្រោយ? ហេតុអ្វី?

**ចំ៖** ពិធីការទាក់ទងនិងសកម្មភាពអ្នករៀបចំកម្មវិធី មានក្នុងសៀវភៅយូណៃធីតមេថូឌីស្ទ (ទំព័រ១១) និងសៀវភៅថ្វាយបង្គំយូណៃធីតមេថូឌីស្ទ (ទំព័រ៣៧ និង ៣៩) បង្ហាញថា នំប៉័ងត្រូវបានកាច់បន្ទាប់ពីការអរព្រះគុណ និងការអធិស្ឋានតាមព្រះអម្ចាស់។

វាតាមព្រះគម្ពីរព្រោះវាផ្តល់តំលៃដល់គំរូបួនជ្រុង៖ យក ឲ្យពរ កាច់ និងឲ្យ ដែលមានចែងក្នុងគម្ពីរ ១កូរិនថូស។[24] ក្នុងការរៀបចំតុសំរាប់កម្មវិធី យើងមាននំប៉័ង និងស្រាទំពាំងបាយជូ ទោះជាគ្រាន់តែគ្រប នំប៉័ង និងស្រាទំពាំងបាយជូ ឬនាំវាចូលមក ជាចំណែកនៃការថ្វាយដង្វាយ។ បន្ទាប់មកយើងឲ្យពរ ហើយអរព្រះគុណ សំរាប់អំណោយទានទាំងនេះ។ យើងកាច់នំប៉័ង បន្ទាប់ពីអរព្រះគុណ ដើម្បីឲ្យអំណោយទាននេះបានដល់សហគមន៍ដែរ។ យើងយកដើម្បីបានពរ យើងកាច់ ដើម្បីឲ្យ។

ការធ្វើបន្ទាប់ពីពិធីអរព្រះគុណ វាស្រួលអនុវត្ត ព្រោះវាជួយឲ្យយើងផ្តោតអារម្មណ៍លើការអធិស្ឋាន ជាជាងការមើលសកម្មភាពរបស់អ្នកដឹកនាំកម្មវិធី។

---

[22] Hoyt Hickman, *Worship Resources of the United Methodist Hymnal* (Nashville: Abingdon, 1989), 74.

[23] *THM*, “The ritual of the church,” 24.

[24] *THM*, “The Prayer of Great Thanksgiving,” 21; *The United Methodist Book of Worship* (Nashville: United Methodist Publishing House, 1992), 27-29.

# មានអីកើតឡើង?

តាមរយៈការចែកនំបុ័ងនិងពែង យើងទទួលបានបទពិសោធន៍នៃពិធីលៀងព្រះអម្ចាស់ ក្នុងកំរិតគ្រឹះដំបូង វត្តមានរបស់ព្រះក្នុងព្រះគ្រីស្ទ និងការប្រកបជាមួយអ្នកជិតខាង។ នំបុ័ងនិងទឹកទំពាំងបាយជូ ត្រូវបាននាំមកកាន់តុព្រះអម្ចាស់ ហើយសហគមន៍ចូលរួមអាហារបរិសុទ្ធ។ (យើងកត់សម្គាល់ត្រង់នេះថា «ក្រុមជំនុំពីដើម និងក្រុមជំនុំអន្តរនិកាយ ប្រើស្រាទំពាំងជូក្នុងពិធីលៀងព្រះអម្ចាស់។»[25] ទោះបីជាគ្មានការហាមប្រាមណាមួយទាក់ទងនិងស្រាទំពាំងបាយជូ ក្រុមជំនុំយូណៃធីតមេថូឌីស្ទ ប្រើទឹកទំពាំងបាយជូ។) នេះជាបទពិសោធន៍ដែលយើងមានជួយព្រះអម្ចាស់ និងជាមួយអ្នកដទៃតាមរយៈព្រះយេស៊ូវគ្រីស្ទ។ បទពិសោធន៍នេះឲ្យយើងស្គាល់សេចក្តីស្រឡាញ់ សេចក្តីមេត្តា និងព្រះគុណរបស់ព្រះ ទោះបីជាយើងមិនអាចពន្យល់ ថាការទាំងនេះកើតឡើងយ៉ាងម៉េចក៏ដោយ។[26]



បទពិសោធន៍នៃសេចក្តីស្រឡាញ់របស់ព្រះតាមរយៈពិធីលៀងព្រះអម្ចាស់ និងតាមរយៈពិធីជ្រមុជទឹក ការអានព្រះគម្ពីរ ការអធិស្ឋាន តមអាហារ និងការប្រកបគ្នាជាមួយគ្រីស្ទបរិសទ្ធ បាននាំឲ្យយូណៃធីតមេថូឌីស្ទហៅពីការអនុវត្តន៍នេះជាវិធីនៃព្រះគុណ។ មានន័យថា កាលដែលទ្រង់អាចឈោងមករកយើង ដោយគ្មានកំណត់ ការទាំងនេះគឺជាវិធីតាំងពីដើមរៀងមក សំរាប់រាស្ត្ររបស់ព្រះទទួលបានបទពិសោធន៍នៃព្រះគុណ។[27]

ទោះបីជាវាល្បួងឲ្យយើងជឿថា បទពិសោធន៍នេះជាអ្វីដែលព្រះប្រទានមកយើង លោកចន វេស្លី តែងតែរំលឹកក្រុមជំនុំមេថូឌីស្ទថា បទពិសោធន៍នៃព្រះគុណនេះ ពឹងផ្អែកលើអំណោយទានរបស់ព្រះ និងការឆ្លើយតបរបស់យើង ដោយសេចក្តីជំនឿ។ យើងអាចនិយាយម្យ៉ាងទៀតថា ក្នុងពេលដែលព្រះអញ្ជើញយើងចូលក្នុងពិធីជប់លៀង ការចូលរួមរបស់យើងវាអាស្រ័យការដែលយើងទទួលការអញ្ជើញនោះ។[28]

លោកវេស្លីជឿថា អត្ថប្រយោជន៍នៃការចូលរួមក្នុងពិធីលៀងព្រះអម្ចាស់មានពីរយ៉ាង៖

[25] See *THM*, “The Communion Elements,” 30.

[26] *THM*, “Toward a richer sacramental life,” 9-10.

[27] *THM*, “Grace and the means of grace,” 6-7.

[28] *THM*, “Toward a richer sacramental life,” 10.

អំពើបាបរបស់យើងត្រូវបានអត់ទោស និងយើងមានកំឡាំងក្នុងការស់នៅជីវិតជាគ្រីស្ទបរិសុទ្ធ។[29] គោលគំនិតនៃការអត់ទោស និងកំឡាំង បន្តជាការសំខាន់សំរាប់យុំណៃធីតមេថូឌីស្ទសព្វថ្ងៃ សំរាប់ការយល់ពីពិធីលៀងព្រះអម្ចាស់។ ប៉ុន្តែដូចដែលយើងបានឃើញក្នុងការពន្យល់នៃពិធីអរព្រះគុណ គោលគំនិតទាំងនេះមានដំណើរការទាំងគំរិតផ្ទាល់ខ្លួន និងសង្គម។ តាមរយៈអាហារបរិសុទ្ធនេះ យើងមានទំនោរទៅកាន់ដួងចិត្ត និងជីវិតបរិសុទ្ធ។

យើងមិនគ្រាន់តែទទួលការអត់ទោសនិងកំឡាំងជាបុគ្គលនៃសេចក្តីជំនឿទេ តែយើងក៏ទទួលអំណោយទានទាំងនេះជាសហគមន៍នៃសេចក្តីជំនឿ។ ក្នុងការអរព្រះគុណ យើងចាំថាព្រះជាម្ចាស់បានឈោងចាប់សហគមន៍នៃសេចក្តីជំនឿ តាមរយៈប្រវត្តិមនុស្សលោកជាមួយនិងពាក្យនៃការសង្គ្រោះ និងការយកចិត្តទុកដាក់ (ឧទាហរណ៍ អេសាយ ៤០៖១-១១)។

យើងចាំថា ព្រះយេស៊ូវនាំពួកសិស្សរបស់ទ្រង់មកជើងភ្នំនៅកាលីឡេ និងក្នុងបន្ទប់ខាងលើដើម្បីរួមអាហារជាមួយគ្នា។

យើងក៏ចាំដែរថាគឺជាមួយនិងពួកសិស្សដែលមានការភ័យខ្លាចបន្ទាប់ពីព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ (យ៉ូហាន ២០៖១៩-២៣) និងជាមួយសហគមន៍ចំរុះជាតិសាសន៍នៅទីក្រុងយេរ៉ូសាឡឹមក្នុងថ្ងៃបុណ្យទី៥០ (កិច្ចការ ២៖១-៤២) ដែលព្រះចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធនៃការ អត់ទោស និងអំណាច។ កំលាំងដែលយើងទទួលក្នុងពិធីលៀងព្រះអម្ចាស់គឺជាកំលាំងនៃសហគមន៍នៃសេចក្តីជំនឿ។ ព្រះវិញ្ញាណបរិសុទ្ធបានបង្ហូរលើនំប៉័ងនិងទឹកទំពាំងបាយជូ និងដល់សហគមន៍ដែលប្រជុំគ្នា ដែលយើងគ្រប់គ្នាជារូបកាយនៃព្រះគ្រីស្ទសំរាប់ពិភពលោក និងយើងជាពន្ធកិច្ចនិងការបំរើក្នុងពិភពលោក។

---

[29] *THM*, “The issue of ‘unworthiness,’” 17-18.



# វត្តមានពិតរបស់ព្រះគ្រីស្ទ

សំនួរមួយនៃពិធីលៀងព្រះអម្ចាស់ដែលគេសួរតាំងពីសម័យមជ្ឈិមសម័យ និងសម័យក្រុមជំនុំប្រូតេស្តង់កើតឡើង គឺថាតើវត្តមានព្រះគ្រីស្ទមានទំនាក់ទំនងអ្វីជាមួយនំប៉័ង និងទឹកទំពាំងបាយជូរ។[30] ចំលើយសំរាប់សំនួរនៃព្រះវត្តមានពិតរបស់ព្រះគ្រីស្ទក្នុងនំប៉័ងនិងទឹកទំពាំងបាយជូរ វាអាស្រ័យលើទស្សនៈវិទ្យាសម័យនោះ។

លោកវេស្លីទទួលស្គាល់ពីសារៈសំខាន់នៃសំនួរនេះ ប៉ុន្តែគាត់ចង់ផ្តល់អ្វីដែលជាក់ស្តែងជាជាងចំលើយបែបទស្សនៈវិជ្ជា។ គាត់ចង់ឲ្យយើងផ្តោតអារម្មណ៍លើភាពពិតនៃវត្តមានរបស់ព្រះគុណ ក្នុងព្រះយេស៊ូវគ្រីស្ទ ក្នុងពិធីលៀងព្រះអម្ចាស់។ ចំរៀងរបស់លោក ឆាល វេស្លី «ជម្រៅនៃសេចក្តីស្រឡាញ់របស់ព្រះ» ផ្តល់ជាការសង្ខេបនៃការឆ្លើយតប និងការឆ្លើយនៃយូណៃធីតមេថូឌីស្ទសព្វថ្ងៃ។

ជម្រៅនៃសេចក្តីស្រឡាញ់របស់ព្រះ
ព្រះគុណដែលមិនអាចវាស់បាន
មានក្នុងនំប៉័ងនិងទឹកទំពាំបាយជូ
ព្រះបង្រៀនយើង
នំប៉័ង ជារូបកាយទ្រង់ដែលបែកបាក់
ទឹកទំពាំងបាយជូជាលោហិត
បំពេញដួងចិត្តអ្នកដែលស្រឡាញ់ទ្រង់
ជាមួយនិងជីវិតរបស់ព្រះ។

[30] *THM*, “The Presence of Christ,” 11-13.

សូមអ្នកដែលឆ្លាតបានដឹង
របៀបដែលយើងទទួលព្រះគុណ
ចំណិតនំប៉័ងនិងទឹកទំពាំងបាយជូបានឲ្យមកយើង
វាមិនអាចផ្តល់កំឡាំងទេ
អ្នកណាអាចពន្យល់ការនេះបាន
តើគោលគំលៃបានមកពីណា?
គោលគំលៃពិតជាមាន
តែនៅដដែល។

តើវិញ្ញាណមកពីស្ថានសួគ៌កើតមាន
ដោយសារអាហារនៅផែនដី
ភេសជ្ជៈដែលផ្តល់មកពីស្ថានសួគ៌
និងបរិភោគនំបុ័ង?
សួរប្រាជ្ញារបស់ព្រះ
ព្រះគ្រីស្ទដែលបានបំពេញការនេះ
ទេវតានៅជុំវិញអោយក្បាល
ដើម្បីឲ្យដឹងការទាំងនេះ។

ព្រះគុណគឺពិតប្រាកដ
អកប្បកិរិយាមិនដឹង
សូមជួបទូលបង្គំដោយវិធីរបស់ទ្រង់
ហើយជួយឲ្យទូលបង្គំបានល្អឥតខ្ចោះ
សូមឲ្យទូលបង្គំភ្លក់រស់ជាតិអំណាចស្ថានសួគ៌
ទូលបង្គំមិនសូមអ្វីច្រើនជាងនេះទេ។
សូមទ្រង់ប្រទានពរ
ឲ្យទូលបង្គំស្រឡាញ់និងពេញចិត្ត។[31]

ចំរៀងនេះប្រាប់ថា ពេលដែលយើងបន្តធ្វើការយល់ពីវត្តមានរបស់ព្រះគ្រីស្ទនៅលើតុ យើងត្រូវយល់ឲ្យច្បាស់ថាពីការដែលព្រះបង្ហាញព្រះគុណ និងសេចក្តីស្រឡាញ់ទ្រង់។ វាគ្រប់គ្រាន់ហើយដែលយើងដឹងថា ក្នុងការទទួលចំណិតនំប៉័ងនិងទឹកទំពាំងបាយជូ យើងបានភ្លក់រស់ជាតិនៃសេចក្តីស្រឡាញ់របស់ព្រះសំរាប់យើង ការអត់ទោសអំពើបាប ជីវិតដែលបានរីកចំរើនឡើងទាំងអស់គ្នា និងកំឡាំងនៃការបំរើពិភពលោក។

31 Charles Wesley, “O the depth of love divine” in *The United Methodist Hymnal*, 627.

# អ្នកណាអាចទទួល?

សាក្សីនៃសហគមន៍គ្រីស្ទបរិសុទ្ធដំបូង ក្នុងគម្ពីរសញ្ញាថ្មី បង្ហាញថាអ្នកដែលឆ្លើយតបនិងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ចាប់ផ្ដើមជីវិតរបស់គេក្នុងសហគមន៍គ្រីស្ទបរិសុទ្ធតាមរយៈពិធីជ្រមុជ។[32] នេះក្លាយជាចំនុចចាប់ផ្ដើមចូលក្នុងជីវិតនៃក្រុមជំនុំ។ ពេលចូលក្នុងសហមគមន៍តាមរយៈពិធីជ្រមុជទឹក ចូលទៅក្នុងការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ពួកគេទទួល បានការជួយពង្រឹងឲ្យរីកចំរើមតាមរយៈ «ការបង្រៀន និងការប្រកបរបស់ពួកសាវក្ស ការកាច់នំប៉័ង និងការអធិស្ឋាន» (កិច្ចការ ២៖៤២)។ ក្រុមជំនុំដើមពិពណ៌នាទំនាក់ទំនងរវាងពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ ជាទំនាក់ទំនងរវាងកំណើត និងការទ្រទ្រង់ដែលចាំបាច់សំរាប់ការរីកចំរើនបន្ទាប់ពីចាប់កំណើត។ តាមវិធីនេះអាហារបរិសុទ្ធគឺសំរាប់បញ្ជាក់ពីការអត់ ទោសអំពើបាបដែលយើងទទួល និងព្រះគុណដែលព្រះបន្តផ្ដល់ឲ្យយើងក្នុងព្រះគ្រីស្ទ។

ក្នុងប្រវត្តិ និងជីវិតក្រុមជំនុំ ពិធីជ្រមុជទឹក ត្រូវបានប្រើជាពិធីនាំចូលមកកាន់ពិធីលៀងព្រះអម្ចាស់។[33] ដោយការកំណត់តុព្រះអម្ចាស់ សំរាប់តែអ្នកទទួលពិធីជ្រមុជទឹក ក្រុមជំនុំចង់ឲ្យកម្មវិធីនេះគឺសំរាប់តែអ្នកដែលបរិសុទ្ធ។ ការកំណត់នេះក៏ចេញពីការយល់របស់ក្រុមជំនុំដែលថា វាទាមទារឲ្យមានការបង្កើតជីវិតជាគ្រីស្ទបរិសុទ្ធថ្មី មុនពេលដែលអ្នកណាម្នាក់អាចចូលរួមប្រកបក្នុងតុព្រះអម្ចាស់។ ក្រុមជំនុំតែងតែផ្លាស់ប្ដូគំនិត ថាគួរឲ្យកុមារដែលទទួល ពិធីជ្រមុជទឹក និងអ្នកដែលមានបញ្ហាខួក្បាលដែលបានទទួលពិធីជ្រមុជទឹក អាចទទួលពិធីលៀងព្រះអម្ចាស់ឬអត់។ បើពិធីជ្រមុជទឹក ជាពិធីសំរាប់ចូលក្នុងតុព្រះអម្ចាស់ នោះពិធីលៀងព្រះអម្ចាស់ គឺជាសិទ្ធិរបស់អស់អ្នកដែលបានទទួលពិធីជ្រមុជទឹក ទោះបីគេអាយុប៉ុន្មាន ហើយមានពិការភាពឬអត់។[34]

បើអញ្ចឹង តើពិធីលៀងព្រះអម្ចាស់ដែលបើកចំហរ មានន័យដូចម្ដេច? ចលនាមេថូឌីស្ទក្នុងប្រទេសអង់គ្លេសលើកដំបូង នាំឲ្យមានការពិបាកសំរាប់ក្រុមជំនុំក្នុងការយល់ពីការអនុវត្តន៍ពិធីលៀងព្រះអម្ចាស់។ ម្យ៉ាងទៀត មនុស្សភាគច្រើនក្នុងក្រុមជំនុំប្រទេសអង់គ្លេសបានទទួលពិធីជ្រមុជទឹកកាលពីក្មេង។ ទោះបីជាពិធីលៀងព្រះអម្ចាស់គឺជាសិទ្ធិរបស់គេ មានមនុស្សតិចណាស់ដែលចូលរួមក្នុងពីធីលៀងព្រះអម្ចាស់។ ដើម្បីឆ្លើយតបចំពោះការនេះ

[32] *THM*, "Invitation to the Lord's Table," 14.

[33] *THM*, "Invitation to the Lord's Table," 14.

[34] *THM*, "Invitation to the Lord's Table," 15.

លោកវេស្លី លើកទឹកចិត្តឲ្យមេថូឌីស្ទទទួលពិធីលៀងព្រះអម្ចាស់ឲ្យកាន់តែញឹកញាប់។[35] ម៉្យាងទៀត លោកវេស្លីយល់ថា ពិធីជ្រមុជទឹកមិនបានធានាភាពបរិសុទ្ធសំរាប់អស់អ្នកដែលប្រជុំគ្នាក្នុងពិធីលៀងព្រះអម្ចាស់ទេ។ ដើម្បីឆ្លើយតបចំពោះការនេះ លោកវេស្លី បានរៀបចំឲ្យ គ្រីស្ទបរិសទ្ធភ្ញាក់ឡើងចំពោះសេចក្តីជំនឿក្នុងព្រះគ្រីស្ទ និងក្នុងការចាប់កំណើតជាថ្មីក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ វាជាភស្តុតាសំរាប់អ្នកដែលភ្ញាក់ឡើងក្នុងសេចក្តីជំនឿតាមរយៈពិធីលៀងព្រះអម្ចាស់ ដែលធ្វើឲ្យលោកវេស្លីយល់ថាពិធីលៀងព្រះអម្ចាស់អាចផ្លាស់ប្តូរ មនុស្ស ហើយនាំឲ្យមនុស្សរស់ជីវិតថ្មីក្នុងព្រះគ្រីស្ទ។ ទោះជាយ៉ាងនេះក៏ដោយ លោកវេស្លីយល់ថា អ្នកដែលភ្ញាក់ក្នុងសេចក្តីជំនឿ ហើយចូលរួមក្នុងតុព្រះអម្ចាស់ បានទទួលពិធីជ្រមុជទឹក។[36]

ការយល់ថាពិធីលៀងព្រះអម្ចាស់ជាការបញ្ជាក់ និងធ្វើឲ្យផ្លាស់ប្រែ គឺជាហេតុធ្វើឲ្យយូណៃធីតមេថូឌីស្ទ ធ្វើពិធីលៀងព្រះអម្ចាស់ដោយចំហរ។ អ្នកដែលចង់រស់នៅជាជីវិតគ្រីស្ទានមិនថា អាយុប៉ុន្មាន ឬកាយសម្បទា ឬនិកាយណានោះទេ គឺត្រូវបានអញ្ជើញចូលរួមក្នុងពិធីលៀងព្រះអម្ចាស់។ (ក្រុមជំនុំដែលអនុវត្តន៍ពិធីលៀងព្រះអម្ចាស់មិនបើកចំហរ មិនអនុញ្ញាតិឲ្យអ្នកណាចូលរួម លើកលែងតែ សមាជិក និងបានទទួលពិធីជ្រមុជទឹកពីនិកាយរបស់គេ។ ពេលយើងទៅថ្វាយបង្គំជាភ្ញៀវ យើងគួរគោរពតាមច្បាប់របស់គេ។[37])

ក្នុងក្រុមជំនុំយូណៃធីមេថូឌីស្ទជាច្រើន ការអញ្ជើញមនុស្សឲ្យចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ រួមមានទាំងការរំលឹកថា ព្រះយេស៊ូវបានបរិភោគជាមួយមនុស្សមានបាប និងមនុស្សសុច្ចរិតផងដែរ។ យើងក៏រំលឹកដែរថា ពិធីលៀងព្រះអម្ចាស់មិនមែនជារបស់និកាយណាមួយ នោះទេ តែវាជារបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះគ្រីស្ទអញ្ជើញយើងឲ្យចូលរួមជាមួយទ្រង់។[38]

ដូច្នេះវាមានភាពតានតឹងរវាងតុព្រះអម្ចាស់ដែលបើកចំហរ និងគោលលិទ្ធិរបស់ក្រុមជំនុំ។ យើងមិនដែលបដិសេធន៍អ្នកណាម្នាក់ដែលចង់ចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ទេ។ បើមិនធ្វើដូចនេះទេ គឺយើងធ្វើផ្ទុយពីព្រះគុណរបស់ព្រះ។ ម៉្យាងទៀត ដោយទឹក និងព្រះវិញ្ញាណ ក្រុមជំនុំយូណៃធីតមេថូឌីស្ទប្រកាសក្នុងពិធីជ្រមុជទឹកថាៈ

---

[35] *THM*, “Invitation to the Lord’s Table,” 19.

[36] *THM*, “Invitation to the Lord’s Table,” 15.

[37] *THM*, “Holy Communion and the unity of the church,” 38.

[38] *THM*, “Invitation to the Lord’s table,” 13-14.

> ក្នុងការប្រារព្ធពិធីលៀងព្រះអម្ចាស់ យើងនឹកចាំពីព្រះគុណដែលបានឲ្យមកយើង ក្នុងពិធីជ្រមុជរបស់យើង និងចូលរួមក្នុងអាហារខាងវិញ្ញាណ ដើម្បីបំពេញសេចក្ដីសន្យានៃសេចក្ដីសង្គ្រោះ... អ្នកដែលមិនទាន់ទទួលពិធីជ្រមុជទឹក ដែលទទួលពិធីលៀងព្រះអម្ចាស់ គួរទទួលបានការប្រឹក្សាយោបល់ ដើម្បីគេអាចទទួលពិធីជ្រមុជទឹកកាន់តែឆាប់ តាមដែលអាចធ្វើបាន។

អំណោយទាននេះទាមទារឲ្យយើងឆ្លើយតបដោយសេចក្ដីជំនឿដែលនាំឲ្យមានការតាំងចិត្ត។[39]

## សំនួរពីអ្នកដែលអាចទទួលបាន

**សំ៖** តើអ្នកត្រូវមានអាយុប៉ុន្មានដែលអាចចូលរួមពិធីលៀងព្រះអម្ចាស់បាន? តើអ្នកត្រូវទទួលពិធីជ្រមុជទឹកមុនឬ? តើអ្នកត្រូវជាសមាជិកក្រុមជំនុំឬ?

**ចំ៖** ក្រុមជំនុំយូណៃធីតមេថូឌីស្ទ មិនកំណត់អាយុ ឬសមាជិកភាព ក្នុងការចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ទេ។ គោលការណ៍នៃអត្ថន័យនិងការអនុវត្តន៍នៃពិធីជ្រមុជទឹក មានចែងក្នុងសៀវភៅថ្វាយបង្គំរបស់យូណៃធីតមេថូឌីស្ទ និងសៀវភៅដែលមានចំណងជើងថា ដោយទឹកនិងដោយវិញ្ញាណ។ សៀវភៅថ្វាយបង្គំចែងថា «អស់អ្នកដែលចង់រស់នៅជាជីវិតគ្រីស្ទបរិសទ្ធ រួមទាំងក្មេងៗដែរ ត្រូវបានអញ្ជើញមកទទួលនំប៉័ង និងទឹកទំពាំងបាយជូ។»[40] សៀវភៅ ដោយទឹកនិងវិញ្ញាណក៏មានចែងស្រដៀងគ្នាដែរថា «ដោយសារអាហារនេះជារបស់ព្រះអម្ចាស់ វាគួរតែបើកចំហរ ដល់អ្នកដែលឆ្លើយតបនិងសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទ ទោះបីជាអាយុប៉ុន្មាន ឬជាសមាជិកក្រុមជំនុំឬអត់។»[41] ដូច្នេះយើងមានការទទួលខុសត្រូវ «ផ្ដល់ការបង្រៀន ពីពិធីវិសុទ្ធនេះដល់មនុស្សគ្រប់វ័យ។[42]

---

[39] *THM*, "Invitation to the Lord's table," 14-15.

[40] *United Methodist Book of Worship*, 29.

[41] "By Water and the Spirit: A United Methodist Understanding of Baptism" in *The Book of Resolutions of The United Methodist Church* - 2012 (Nashville: United Methodist Publishing House, 2012), 939.

[42] *THM*, "Invitation to the Lord's Table," 14.

ចំពោះសំនួរដែលថាពិធីលៀងព្រះអម្ចាស់ទាមទារឲ្យមាន ពិធីជ្រមុជទឹក សៀវភៅ អាចកំបាំងបរិសុទ្ធ បញ្ជាក់ពីភាពតានតឹងរវាងការស្វាគមន៍នៃដំណឹងល្អ និងគោលការណ៍ គ្រីស្ទបរិសទ្ធ ដែលយើងបានពិភាក្សាក្នុងវគ្គមុន។ ម៉្យាង «អ្នកដែលមិនទាន់ទទួលពិធីលៀងព្រះអម្ចាស់ ដែលឆ្លើយតបដោយសេចក្ដីជំនឿចំពោះការអញ្ជើញ នោះនឹងត្រូវបានស្វាគមន៍មកក្នុងតុព្រះអម្ចាស់។»[43] ម៉្យាងទៀត «ពិធីជ្រមុជទឹកជាទូទៅកើតមុនពេលទទួលពិធីលៀងព្រះអម្ចាស់។ ពិធីលៀងព្រះអម្ចាស់គឺជាអាហារសហគមន៍ ដែលមានសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់តាមរយៈព្រះយេស៊ូវគ្រីស្ទ។»[44]

[43] *THM*, “Invitation to the Lord’s Table,” 15.

[44] *THM*, “Invitation to the Lord’s Table,” 14.

# អ្នកណាដែលសាកសម?

ដែលជ្រៅជាងសំនួរអំពី ពិធីលៀងព្រះអម្ចាស់ជាចំហរ ឬមិនចំហរ គឺជាការបារម្មណ៍ចំពោះការចែករំលែកពិធីលៀងព្រះអម្ចាស់ដោយរបៀបដែលសាកសម។[45] ការបារម្មណ៍នេះកើតចេញពីការរំពឹកទុករបស់ក្រុមជំនុំ ចំពោះអំណោយទានដ៏បរិសុទ្ធ នៃនំបុ័ងនិងទឹកទំពាំងបាយជូរ គឺត្រូវចែកឲ្យមនុស្សបរិសុទ្ធតែប៉ុណ្ណោះ។ ការបារម្មណ៍ពីភាពសាកសមរបស់យើងនេះ បន្តបើកសំដែងក្នុង «សេចក្តីអធិស្ឋានដោយបន្ទាបខ្លួន» ដែលជាផ្នែកមួយនៃការថ្វាយបង្គំរបស់មេថូឌីស្ទ តាំងពីដើមមក។ មានយូណៃធីតមេថូឌីស្ទជាច្រើនដែលបានធំពេញវ័យដោយការឮសេចក្តីអធិស្ឋាន «ទូលបង្គំមិនសាកសមទទួលកំទេចនំបុ័ងក្រោមតុរបស់ទ្រង់ផង»។ ឃ្លាមួយនេះផ្តល់ជាស្រមោលដល់ឃ្លាបន្ទាប់ ដែលរំលឹកយើងពីសេចក្តីមេត្តាករុណារបស់ព្រះ «តែព្រះអម្ចាស់នៅដដែល ដែលទ្រង់តែងមានសេចក្តីមេត្តាករុណា។»[46]



ការបារម្មណ៍ចំពោះភាពសាកសមក្នុងការទទួលបានវិវឌ្ឍន៍ចេញមកពីការយល់ច្រលំចំពោះការព្រមានរបស់សាវក្យប៉ុល ក្នុង ១កូរិនថូស១១៖២៧-២៩៖

> បានជាអ្នកណាដែលបរិភោគនំបុ័ងនេះ ឬផឹកពីពែងនៃព្រះអម្ចាស់បែបមិនគួរសម នោះនឹងមានទោសចំពោះរូបអង្គ ហើយនិងព្រះលោហិតនៃព្រះអម្ចាស់ ត្រូវឲ្យមនុស្សល្បងខ្លួនឯងមើល រួចសឹមបរិភោគនំបុ័ង ហើយផឹកពីពែងនេះចុះ ដ្បិតអ្នកណាដែលបរិភោគបែបមិនគួរសម អ្នកនោះឈ្មោះថាបរិភោគជាសេចក្តីជំនុំជំរះដល់ខ្លួនវិញ ដោយព្រោះមិនពិចារណាឃើញរូបអង្គនៃព្រះអម្ចាស់ទេ។

[45] *THM*, “The issue of ‘unworthiness,’” 17-18.

[46] “A Service of Word and Table IV” in *The United Methodist Hymnal*, 30.

លោកប៉ុល សរសេរខនេះដើម្បីនិយាយពីការធ្វើខុសចំពោះអាហារពិសេសនេះ ក្នុងក្រុមជំនុំនៃទីក្រុងកូរិនថូស មិនមែនជាសំនួរថាតើអ្នកណាសាកសមឬអត់នោះទេ។ ការព្រមានរបស់ លោកប៉ុល បានឲ្យអ្នកយកចិត្តទុកដាក់ចំពោះការរស់នៅជីវិតបរិសុទ្ធ មិនមែនគ្រាន់តែជាលក្ខណៈបុគ្គលនោះទេ តែជាសហគមន៍ទាំងមូលតែម្តង។ លោកប៉ុល រំលឹកយើងឲ្យយកចិត្តទុកដាក់ចំពោះការរស់នៅជារូបកាយរបស់ព្រះគ្រីស្ទ ក្នុងក្រុមជំនុំ និងពិភពលោក។[47]

ក្នុងបទចំរៀងរបស់លោក ឆាល វេស្លី «អ្នកមានបាប ចូលមកជប់លៀងដំណឹងល្អ» ជួយឲ្យយើងយល់ពីការបើកចំហរចំពោះពិធីលៀងព្រះអម្ចាស់ ដែលយើងសាកសមនិងបរិភោគ។

អ្នកមានបាបចូលមកជប់លៀងដំណឹងល្អ
សូមឲ្យគ្រប់វិញ្ញាណទាំងអស់មកជាភ្ញៀវរបស់ព្រះគ្រីស្ទ
អ្នកមិនមែនជាអ្នកដែលសល់ចុងក្រោយទេ
ព្រោះព្រះបានលោះបាបមនុស្សគ្រប់គ្នា។

សូមកុំចាប់ផ្តើមរកលេស
សូមអ្នកកុំបដិសេធន៍ព្រះគុណទ្រង់
សូមដកចេញរាល់សេចក្តីសប្បាយលោកិយ៍
ហើយទទួលអ្វីដែលព្រះគ្រីស្ទប្រទាន។[48]

ទោះបីយើងជាអ្នកណាក៏ដោយ ព្រះអម្ចាស់ប្រទានឲ្យយើងម្នាក់ៗនូវពិធីជប់លៀងនៃដំណឹងល្អ។ ព្រះយេស៊ូវឈររងចាំទទួលយើង។ យើងជាអ្នកទទួលយកការអញ្ជើញនេះ។

---

[47] *THM*, “The issue of ‘unworthiness,’” 18.

[48] Charles Wesley, “Come, sinners, to the gospel feast,” ក្នុង សៀវភៅចំរៀងមេថូឌីស្ទ 616.

# ញឹកញាប់ប៉ុណ្ណា?

ចលនាលោកវេស្លីជាការរីកឡើងវិញទាំងផ្នែកជំណឹងល្អ និងពិធីវិសុទ្ធ។ ប៉ុន្តែ ទំនាក់ទំនងរវាង ក្រុមជំនុំមេថូឌីស្ទ និងក្រុមជំនុំអង់គ្លេស ក៏ដូចជាចលនាមេថូឌីស្ទនៃប្រទេសអាមេរិក ធ្វើឲ្យមានការពិបាក ក្នុងការប្រកាន់ភ្ជាប់ចំណុចទាំងពីរនេះ។[49] ប្រវត្តិនៃមេថូឌីស្ទនៅអាមេរិកខាង ជើង មានភាពខុសគ្នាចំពោះភាពញឹកញាប់នៃការប្រារព្ធពិធីលៀងព្រះអម្ចាស់ ។ ក្រុមជំនុំដំបូង ក៏ដូចជាខាងប្រូតេស្តង់ (ដូចជាលោក ម៉ាទីន លូធើ និង ចន ខាលវិន) ចង់ឲ្យមានពិធីលៀងព្រះអម្ចាស់រាល់ថ្ងៃព្រះអម្ចាស់។ ប៉ុន្តែយើងដឹងតាំងពីប្រវត្តិសាស្ត្រនៃក្រុមជំនុំថា មានជំលោះរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង។

សម័យលោកវេស្លី ក្រុមជំនុំតាមជនបទ អាចទទួលពិធីលៀងព្រះអម្ចាស់៣ខែម្តង។ ក្រុមជំនុំក្នុងក្រុង ធ្វើញឹកញាប់ជាង។ ច្បាប់របស់ក្រុមជំនុំប្រទេសអង់គ្លេស តម្រូវឲ្យគ្រីស្ទបរិសទ្ធ ទទួលពិធីលៀងព្រះអម្ចាស់ យ៉ាងតិចម្តង ក្នុងថ្ងៃព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ ។ ផ្នែកមួយនៃការមិនចង់ឲ្យមានពិធីលៀងព្រះអម្ចាស់ញឹកញាប់ គឺដោយសារភាពសាកសមនៃការទទួល (ដូចដែលបាននិយាយវគ្គមុន) និងសេចក្តីត្រូវការចំពោះការរៀបចំខ្លួនដើម្បីទទួលពិធីនេះ។

បរិបទនេះមានក្នុងបទអធិប្បាយលោកចនវេស្លី «ភារៈកិច្ចនៃពិធីលៀងព្រះអម្ចាស់»។ លោកវេស្លី មានយោបល់ថា ភារៈកិច្ចរបស់គ្រីស្ទបរិសទ្ធ ដើម្បីទទួលពិធីលៀងព្រះអម្ចាស់ គឺញឹកញាប់តាមដែលគេអាចធ្វើបាន។[50] គាត់និយាយថា ព្រះមិនមែនចង់ឲ្យយើងស្តាប់បង្គាប់ទ្រង់ ម្តងម្កាលនោះទេ។ ចំពោះសំនួរទាក់ទងនិងភាពសាកសម និងការចង់ឲ្យមានការរៀបចំឲ្យបានសមរម្យ លោកវេស្លីបានសូមឲ្យមេថូឌីស្ទ មានជាទម្លាប់ក្នុងការត្រៀមចិត្តទទួល។ ហើយគាត់រំលឹកយើងថា ព្រះអម្ចាស់មានសេចក្តីមេត្តាករុណា ទោះបីយើងមិនសាកសមក៏ដោយ។

ការដែលក្រុមជំនុំមេថូឌីស្ទក្នុងប្រទេសអាមេរិកពីដើម មិនបានទទួលពិធីលៀងព្រះអម្ចាស់ញឹកញាប់ ដោយសារខ្វះគ្រូគង្វាលដែលមានប្រេងតាំង ដើម្បីរៀបចំពិធីនេះ។ ការបារម្ភណ៍ពីពិធីវិសុទ្ធចំពោះមេថូឌីស្ទអាមេរិកនេះហើយ ដែលធ្វើឲ្យលោកវេស្លី ត្រូវធ្វើការចាក់ប្រេង

[49] *THM*, “American Methodism,” 6.

[50] *THM*, “The basic pattern of worship,” 19. បទអធិប្បាយរបស់លោកវេស្លីមានក្នុង http://www.umcmission.org/Find-Resources/John-Wesley-Sermons/ Sermon-101-The-Duty-of-Constant-Communion (accessed 16 December 2015).

តាំង អ្នកអធិប្បាយមេថូឌីស្ទ។ លោកវេស្លី ផ្តល់ដំបូន្មានដល់អែលឌឺ ឲ្យប្រារព្ធពិធីលៀង ព្រះអម្ចាស់ រាល់ថ្ងៃរបស់ព្រះអម្ចាស់។[51]

ពិធីលៀងព្រះអម្ចាស់មិនត្រូវបានធ្វើញឹកញាប់ក្នុងក្រុមជំនុំមេថូឌីស្ទប្រទេសអាមេរិក ក្នុង សត្តវត្សទី១៩ និង ២០ ដោយសារហេតុផលច្រើនយ៉ាង។ នៅជនបទ ការដែលគ្រូគង្វាល មានប្រេងតាំង មិនបានចុះទៅជារៀងរាល់ពេល ធ្វើឲ្យពិបាកក្នុងការធ្វើពិធីនេះរាល់ថ្ងៃ អាទិត្យ។ អ្នកខ្លះគិតថា ការដែលយើងធ្វើពិធីនេះញឹកញាប់ពេក ធ្វើឲ្យយើងសាំ ហើយមិន មានការ ត្រៀមខ្លួនដើម្បីទទួលពិធីនេះ។ ការប្រជុំតាមជំរំ ក្នុងដើមសត្តវត្សទី១៩ គឺជាឱ កាសនៃពិធីវិសុទ្ធ ព្រោះបន្ទាប់ពីការអធិប្បាយ នឹងមានការសំរេចចិត្តតាមព្រះគ្រីស្ទ ហើយ ធ្វើពិធីជ្រមុជទឹក និងធ្វើពិធីលៀងព្រះអម្ចាស់។ ទោះជាយ៉ាងនេះក៏ដោយ ការដែល ក្រុមជំនុំបារម្ភណ៍ពីការសន្ទនានៃសេចក្តីជំនឿនៅប្រទេសអាមេរិក វាធំជាងការបារម្ភណ៍ ចំពោះការពង្រឹងសេចក្តីជំនឿដោយពិធីវិសុទ្ធ។ ក្នុងសម័យយើងនេះ យើងមានការបារម្ភ ណ៍ពីពេលវេលា ជាជាងការសាកសាមរបស់បុគ្គល និងការផ្លាស់ប្រែជីវិត។

ទោះជាការបារម្ភណ៍ពីភាពញឹកញាប់ បន្តមកដល់ថ្ងៃនេះក៏ដោយ ការសន្ទនាអន្តរនិកាយ អស់រយៈពេលបីបួនទស្សវត្ត ការសិក្សាស្រាវជ្រាវ និងការថ្វាយបង្គំ ជំរុញឲ្យមេថូឌីស្ទមាន តុល្យភាពចំពោះការប្រារព្ធរាល់អាទិត្យ អ្នកខ្លះធ្វើក្នុងម៉ោងពិសេស អ្នកខ្លះធ្វើក្នុងកម្មវិធី ថ្ងៃអាទិត្យ។ ក្រុមជំនុំភាគច្រើនក្នុងប្រទេសអាមេរិក ធ្វើពិធីលៀងព្រះអម្ចាស់មួយខែម្តង ជាទូទៅគឺនៅដើមខែ។ ខ្លះក៏ធ្វើពិធីនេះក្នុងកម្មវិធីពិសេស ដូចជា បុណ្យកំណើតព្រះយេស៊ូវ Epiphany ថ្ងៃព្រហស្បត៍បរិសុទ្ធ ថ្ងៃព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញ និងថ្ងៃបុណ្យ ទី៥០។ ទោះជាគេមិនសូវធ្វើក៏ដោយ ការប្រារព្ធពិធីនេះរាល់សប្តាហ៍ គឺជារឿងធម្មតារបស់ គ្រីស្ទបរិសទ្ធ។[52]

ចុងបញ្ចប់ ការអញ្ជើញ និងចំណង់ចិត្តទទួលការអញ្ជើញនេះ នាំយើងមកទទួលអាហារ ជាមួយព្រះគ្រីស្ទ និងសហគមន៍គ្រីស្ទបរិសទ្ធ។ ការទទួលព្រះគុណរបស់ព្រះ លើកទឹកចិត្ត ឲ្យយើងត្រឡប់មកវិញញឹកញាប់។[53]

---

[51] *THM*, “The basic pattern of worship,” 19.

[52] *THM*, “The basic pattern of worship,” 19-20.

[53] *THM*, “Invitation to the Lord’s table,” 13.

## សំនួរអំពីភាពញឹកញាប់ និងពេលវេលា

**សំ៖** មានសមាជិកក្រុមជំនុំខ្ញុំជាច្រើន ដែលមិនទៅព្រះវិហារ នៅថ្ងៃដែលយើងធ្វើពិធីលៀងព្រះអម្ចាស់ ព្រោះគេមិនចូលចិត្ត។ តើយើងត្រូវតែធ្វើពិធីលៀងព្រះអម្ចាស់ នៅថ្ងៃអាទិត្យដើមខែ ឬយើងអាចធ្វើវាក្នុងឱកាសពិសេស?

**ចំ៖** ចំលើយសំរាប់សំនួរនេះមានពីកម្រិត។ ទីមួយត្រូវដឹងថាហេតុអ្វីបានជាក្រុមជំនុំរបស់អ្នកមិនមកក្រុមជំនុំថ្ងៃមានពិធីលៀងព្រះអម្ចាស់? បើបារម្មណ៍ថាគេយល់ឬមិនយល់ពីអត្ថន័យនៃពិធីលៀងព្រះអម្ចាស់ នោះអ្នកមានឱកាសបង្រៀនក្រុមជំនុំរបស់អ្នក។ សៀវភៅអាចកំបាំងបរិសុទ្ធ បានសរសេរអត្ថប្រយោជន៍នៃចំនុចទាំងពីរនេះ ដែលធ្វើឲ្យជីវិតនៃពិធីវិសុទ្ធកាន់តែមានន័យឡើង[54] និងឱកាសដែលពិធីលៀងព្រះអម្ចាស់ផ្ដល់ឲ្យ ក្នុងការអញ្ជើញមនុស្ស «ចូលក្នុងជីវិតដែលមានទំនាក់ទំនងពេញលេញជាមួយព្រះគ្រីស្ទ។»[55]

បើការបារម្មណ៍ដែលយើងបាននិយាយនេះ ដូចជាការអនុវត្តពិធីលៀងព្រះអម្ចាស់ក្នុង ក្រុមជំនុំរបស់អ្នកដូចជា ស៊ីពេលយូក្នុងកម្មវិធី ឬការគ្មានការយកចិត្តទុកដាក់ចំពោះកម្មវិធី, នោះអ្នកប្រហែលជាត្រូវពិនិត្យឡើងវិញអំពីទំរង់ មាតិការ និងការអនុវត្តកម្មវិធី។ សៀវភៅអមជាមួយសៀវភៅអាចកំបាំងបរិសុទ្ធគឺការរស់នៅក្នុងអាចកំបាំង។ សៀវភៅនេះបានសរសេរពីគោលការណ៍មួយចំនួន «ធ្វើដោយសេចក្ដីពិត។ ចំណាយពេល។ ផ្ដោតលើសកម្មភាព។ ធ្វើក្នុងពេលមនុស្សថ្វាយបង្គំ។ ធ្វើឲ្យល្អបំផុត តាមដែលអ្នកអាចធ្វើបាន។ ហើយបង្ហាញតាមរយៈការដឹកនាំរបស់អ្នកថា នេះជាការចូលរួមក្នុងការថ្វាយបង្គំ ហើយយើងទាំងអស់គ្នាជារូបកាយរបស់ព្រះគ្រីស្ទ ដែលទទួលបានការប្រោសលោះដោះព្រះលោហិត ក្នុងអំណាចនសព្រះវិញ្ញាណបរិសុទ្ធ។»[56]

---

[54] *THM*, "Grace and the Means of Grace," 6-7 and "Toward a richer sacramental life," 9-11.

[55] *THM*, "Invitation to the Lord's Table," 15.

[56] *THM*, "Invitation to the Lord's table," 13.

ចម្លើយទីពីរគឺសំរាប់សំនួរអំពីភាពញឹកញាប់នៃការប្រារព្ធ។ សៀវភៅអាចកំបាំងបរិសុទ្ធ សរសេរថា «អស់អ្នកដែលចង់រស់នៅជាសិស្សរបស់ព្រះគ្រីស្ទមានសេចក្តីត្រូវការជាប្រចាំក្នុងការរីកចំរើន ដែលមានក្នុងព្រះបន្ទូល និងពិធីវិសុទ្ធនៃពិធីលៀងព្រះអម្ចាស់។» ដូច្នេះ ក្រុមជំនុំត្រូវបានលើកទឹកចិត្តឲ្យបន្ត «ប្រារព្ធកម្មវិធីលៀងព្រះអម្ចាស់ រាល់សប្តាហ៍ ក្នុងថ្ងៃព្រះអម្ចាស់។» ហើយក្នុង «ឱកាសពិសេសៗរបស់ក្រុមជំនុំ»[57] អាចនិយាយម្យ៉ាងទៀតថា ការប្រារព្ធពិធីលៀងព្រះអម្ចាស់ក្នុងថ្ងៃអាទិត្យដើមខែ គឺជាអតិបរមា ដែលយើងគួរធ្វើឲ្យបានច្រើនជាងនេះ។

[57] *THM*, “The basic pattern of worship,” 19.



# វិធីនៃការទទួល

ភាពញឹកញាប់ដែលយើងទទួលពិធីលៀងព្រះអម្ចាស់ បញ្ជាក់ពីការយល់ពីអាហារបរិសុទ្ធនេះ។ របៀបដែលយើងទទួលនំប៉ុង និងពែង ក៏បង្ហាញពីការយល់ពីអាហារនេះដែរ។ របៀបដែលយើងទទួលនំប៉ុង និងពែង ក៏បង្ហាញពីប្រវត្តិសាស្ត្រផ្សេងគ្នា ក្នុងទំលាប់របស់ក្រុមជំនុំ ដំណឹងល្អ (Evangelical) និង យូណៃធីតប្រេទ្រិន (United Brethren) និង មេថូឌីស្ទ ដែលត្រូវបានបញ្ចូលគ្នា ក្លាយជាក្រុមជំនុំយូណៃធីតមេថូឌីស្ទ ដែលគ្មានវិធីត្រូវតែមួយណានោះទេ។ មានវិធីជាច្រើនក្នុងការទទួលពិធីលៀងព្រះអម្ចាស់ ហើយវិធីនិមួយៗ បញ្ជាក់ពីការយល់ខុសគ្នានៃអ្វីដែលកំពុងកើតឡើងក្នុងអាហារនេះ។[58]

ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទមួយចំនួន ក្រុមជំនុំទទួលពិធីលៀងព្រះអម្ចាស់ ដោយពួកគេនៅអង្គុយ ហើយថាសនំប៉ុងនិងពែង ត្រូវបានហុចឲ្យពីម្នាក់ទៅម្នាក់។ ព្រះវិហារមួយចំនួនទៀត ក្រុមជំនុំដើរទៅខាងមុខ ដែលពួកគេលុតជង្គង់ ពេលគេទទួលនំប៉ុង និងពែង។ ព្រះវិហារមួយចំនួនទៀត ក្រុមជំនុំដើរទៅកន្លែងពីរបីខាងមុខ ដើម្បីទទួល នំប៉ុង និងពែង។

របៀបផ្សេងៗគ្នានេះ អង្គុយ លុតជង្គង់ ឬឈរ បញ្ជាក់ពីការយល់ឃើញចំពោះពិធីលៀងព្រះអម្ចាស់។

---

[58] *THM*, “The Prayer of Great Thanksgiving,” 22.

អង្គុយពេលដែលអ្នកដទៃនាំយកនំប៉័ងនិងពែងមកឲ្យយើង រំលឹកយើងថា យើងត្រូវបានអញ្ជើញមកអង្គុយចូលរួមក្នុងពិធីជប់លៀង។ វាក៏រំលឹកយើងដែរថា ព្រះយាងមកយើងមុនក្នុងព្រះយេស៊ូវគ្រីស្ទ ដោយផ្ដល់សេចក្តីស្រឡាញ់ និងព្រះគុណ។ ការដែលយើងប្រជុំគ្នាជុំវិញ តុព្រះអម្ចាស់ យើងបម្រើដោយប្រើថាសមាសនិងប្រាក់ ដែលជាតំណាងនៃភាពរុងរឿង នៃពិធីជប់លៀងនេះ។

ពេលយើងដើរទៅកាន់អាសនា ហើយលុតជង្គង់ យើងឆ្លើយតបចំពោះការអញ្ជើញមកកាន់តុព្រះអម្ចាស់។ យើងមកចំពោះការអញ្ជើញរបស់ព្រះអម្ចាស់ ដោយដឹងថា ព្រះអម្ចាស់បានយាងមកកាន់យើងរួចហើយ ហើយទ្រង់កំពុងរងចាំការឆ្លើយតបរបស់យើង។ ការដែលយើងលុតជង្គង់ រំលឹកយើងថា អ្នកដែលអញ្ជើញយើងនេះ ជាព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដី។ បង្កាន់ដៃ ដែលឃាត់មិនឲ្យយើងចូលទៅជិតពេកចំពោះទីបរិសុទ្ធ រំលឹកយើងពីកន្លែងរបស់យើង នៅចំពោះមុខព្រះ។ ការដែលយើងចូលទៅដល់បល្ល័ង្គបរិសុទ្ធរបស់ទ្រង់ក្នុងកាលដែលយើងជាមនុស្សមិនសាកសម យើងត្រូវចូលមកដោយលុតជង្គង់ ហើយអោនក្បាល ដោយទទួលសេចក្តីមេត្តាករុណា និងព្រះគុណទ្រង់ ដោយបន្ទាបខ្លួន។[59]

ចលនាដែលយើងដើរឆ្ពោះទៅកាន់អាសនា យើងឆ្លើយតបចំពោះការអញ្ជើញរបស់ព្រះពេលដែលយើងងើបពីកៅអី និងដើរទៅកាន់កន្លែងទទួលនំប៉័ងនិងពែង។ យើងឮការអញ្ជើញ «សូមមកបរិភោគទាំងអស់គ្នា» យើងដើរចូលមក។ ការដែលយើងឈរនៅតុព្រះអម្ចាស់ គឺជាកាយវិការនៃសេចក្តីអំណរ និងការអរព្រះគុណ។ ការដែលយើងសារភាពបាប និងឮពីការធានានៃការអត់ទោស វាជា «ការត្រឹមត្រូវ និងសេចក្តីអំណរ» ក្នុងការអរព្រះគុណព្រះ ក្នុងពេលដែលយើងមកជុំគ្នាក្នុងតុព្រះអម្ចាស់។[60]

ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទខ្លះ ពិធីលៀងព្រះអម្ចាស់ មានពែងតែមួយ (សំរាប់ក្រុមជំនុំធំ គេមានពែងបីបួន) ហើយកាច់នំប៉័ងមួយដុំ។ ក្រុមជំនុំផ្សេងទៀត ប្រើថាសដែលមានពែងតូចៗ និងចំណិតនំប៉័ងជាច្រើន។

ការប្រើពែងតូចៗ មានប្រជាប្រិយភាពក្នុងសត្តវត្សទី២០ ព្រោះមានការយល់ពីការឆ្លងមេរោគ ជាពិសេសគឺឆ្លើយតបចំពោះការឆ្លងជំងឺគ្រុនផ្ដាសាយធំ (influenza)។ ការធ្វើរបៀបនេះ គឺសំរាប់ថែរក្សាអនាម័យ។ ពេលដែលយើងគិតពីពិធីលៀងព្រះអម្ចាស់ ការប្រើពែងតូចៗ គឺសង្កត់ន័យទៅលើទំនាក់ទំនងរបស់មនុស្សម្នាក់ៗជាមួយព្រះ ជាជាងការដែលយើងប្រកបគ្នា។ ក្រុមជំនុំខ្លះ ឆ្លើយតបការបារម្ភណ៍មួយនេះ ដោយសូមឲ្យក្រុមជំនុំចាំរហូត

---

[59] See the “Prayer of Humble Access” in *The United Methodist Hymnal*, 30.

[60] *The United Methodist Hymnal*, 9.

គ្រប់គ្នាទទួលបានចំណិតនំបុ័ងនិងពែងសិន រួចទើបបរិភោគទាំងអស់គ្នា។[61]

ការប្រើពែងរួម និងនំបុ័ងមួយដុំ មានប្រជាប្រិយក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ។ វាឲ្យយើងផ្តោតអារម្មណ៍ទៅលើរឿងក្នុងព្រះគម្ពីរ នៅបន្ទប់ខាងលើ ដេលព្រះយេស៊ូវហុចពែងមួយ និងកាច់នំបុ័ងមួយដុំជាមួយពួកសិស្ស។[62] វាក៏ជួយឲ្យយើងចាំពាក្យរបស់សាវក្យប៉ុល ក្នុង ១កូរិនថូស ១០៖១៦-១៧៖

> យើងកាច់ នោះតើមិនមែនជាសេចក្តីប្រកបនឹងរូបអង្គនៃព្រះគ្រីស្ទទេឬអី ១៧ ដ្បិតដែលមាននំបុ័ងតែ១ដុំនោះយ៉ាងណា ចំណែកពួកយើងដែលមានគ្នាច្រើន ក៏ជារូបកាយតែ១យ៉ាងនេះដែរ ពីព្រោះយើងទាំងអស់គ្នាទទួលទានពីដុំនំបុ័ងតែមួយនោះឯង

របៀបដែលយើងទទួលពិធីលៀងព្រះអម្ចាស់ក្នុងក្រុមជំនុំយូណៃធីតមេថូឌីស្ទ ជាទូទៅមានការបារម្មណ៍ចំពោះការស៊ីពេលក្នុងកម្មវិធី ជាជាងការដែលជួយឲ្យយើងមានបទពិសោធន៍ ជាមួយព្រះ និងអ្នកជិតខាង។ ទោះយើងអង្គុយ លុតជង្គង់ ឬឈរ ហើយទោះជាយើងប្រើពែងតែមួយ ឬពែងផ្សេងៗគ្នា ការដែលយើងទទួលពិធីលៀងព្រះអម្ចាស់ជួយឲ្យយើងមានទំនាក់ ទំនងជាមួយព្រះ និងជាមួយអ្នកដទៃ។

---

[58] *THM*, "The Communion elements," 30-31.

# សំនួរដែលគេសួរ ញឹកញាប់ផ្សេងទៀត

ក្នុងចំណោមការអនុវត្តន៍ និងការយល់ឃើញ ច្រើនបែបនេះ យើងគួរសួរថា តើមានការប្រារព្ធណាមួយដែលមិនថ្វាយកិត្តិយសពេញលេញ ដល់ប្រយោគទេវវិទ្យាយើងទេ។ ការពិភាក្សាក្នុងកូនសៀវភៅនេះ បង្ហាញពីការបារម្ភណ៍មួយចំនួន។ ទីមួយ គឺក្នុងកំរិតនៃការអនុវត្តន៍ និងនិមិត្តរូប។ វាសំខាន់ណាស់ដែលនំប៉័ងដែលយើងប្រើ គឺជានំប៉័ងពិត ដែលជាការអញ្ជើញការចងចាំនៃទំនាក់ទំនងជាមួយរឿងដែលបានប្រគល់មកយើង ដែលជារឿងពិត ជានំប៉័ងនៃជីវិត។[63]



ទីពីរ យើងនឹកចាំពីការក្រើនរំលឹករបស់សាវក្សប៉ុល ថាយើងយល់ថារូបកាយរបស់ព្រះគ្រីស្ទ នៅកណ្តាលចំណោមពួកយើង។ ដូច្នេះការអនុវត្តន៍ណាដែលមិនឆ្លុះបញ្ចាំងថា អាហារបរិសុទ្ធនេះ ជាទំនាក់ទំនងជាមួយព្រះអម្ចាស់ និងអ្នកជិតខាង—ដូចជាការទទួលពិធីនេះដោយខ្លួនឯង ឬការឈោងចូលទទួលពិធីនេះ ដោយនំប៉័ងនិងពែងត្រូវបានរៀបទុកមុន សំរាប់អ្នកណាចង់ទទួលពេលណាក៏បាន—នោះវាមិនត្រូវតាមគោលបំណង និងការយល់ឃើញរបស់ក្រុមជំនុំយូណៃធីតមេថូឌីស្ទទេ។[64]

ចុងក្រោយ កម្មវិធីណាដែលមិនអនុញ្ញាតិឲ្យអ្នកដែលធ្លាប់ទទួលពិធីជ្រមុជទឹកចូលរួម ជាពិសេស កុមារៗឬអ្នកពិការដែលទទួលពិធីជ្រមុជទឹករួច នោះក៏បរាជ័យក្នុងការឆ្លុះបញ្ចាំងរូប កាយរបស់ព្រះគ្រីស្ទដែរ។[65]

---

[63] *THM*, "The communion elements," 30.

[64] *THM*, "The Communion elements," 32.

[65] *THM*, "Invitation to the Lord's Table," 15-16.

# សំនួរអំពី
# ការប្រារព្ធពិធីវិសុទ្ធ

**សំ៖** តើមេសូត្រ (Liturgy) អ្វីដែលយើងប្រើសំរាប់កម្មវិធីលៀងព្រះអម្ចាស់ ថ្ងៃមុនកំណើតព្រះគ្រីស្ទ «មកហើយទៅ» ? តើគ្រូគង្វាលម្នាក់ត្រូវតែនៅទីនោះគ្រប់ពេល ឬយើងអាចទុកនំបុ័ងនិងពែងដែលយើងអធិស្ឋានឲ្យរួចហើយ នៅលើអាស្នា សំរាប់ឲ្យក្រុមជំនុំមកទទួលដោយខ្លួនឯង?

**ចំ៖** ដូចបាននិយាយពីខាងលើ សៀវភៅអាចកំបាំងបរិសុទ្ធចែងថា «ការអធិស្ឋានឲ្យ នំបុ័ងនិងពែងទុកជាមុន មិនសមរម្យ ហើយផ្ទុយពីគោលលិទ្ធិនិងការយល់ឃើញពីព្រះគុណរបស់ព្រះ ដែលមានក្នុងពិធីវិសុទ្ធ (Article XVIII, The Articles of Religion, BOD; page 64)[66]

គោលការណ៍នេះចេញពីគោលការណ៍ដែលចែងថា នំបុ័ងនិងពែង «ត្រូវបានអធិស្ឋានឲ្យ និងបរិភោគ [ការសង្កត់ន័យរបស់ខ្ញុំ] ក្នុងបរិបទនៃការជួបជុំគ្នារបស់ក្រុមជំនុំ»[67] នេះមានន័យថា ការប្រារព្ធពិធីលៀងព្រះអម្ចាស់ មិនមែនសម័ញ្ញដូចជាការប្រកបជាមួយព្រះតែម្នាក់ឯងនោះទេ។ វាគឺជាការដែលយើងអនុវត្តន៍ការប្រកបជាមួយគ្នា។ «ពិធីលៀងព្រះអម្ចាស់ គឺជាការប្រកបរបស់ក្រុមជំនុំ—ជាសហគមន៍នៃសេចក្តីជំនឿ ទាំងក្នុងតំបន់ និងក្នុងសកលលោក។ ការដែលវាមានន័យយ៉ាងជ្រាលជ្រៅសំរាប់ម្នាក់ៗ ពិធីវិសុទ្ធនេះគឺវាមិនមែនគ្រាន់តែកម្មវិធីឯកជន ប៉ុណ្ណោះទេ។ បទពិសោធន៍នៃការចែករំលែក និងការប្រជុំគ្នា ក្នុងតុព្រះអម្ចាស់ គឺជាធម្មជាតិនៃក្រុមជំនុំ និងជាគំរូនៃដល់ពិភពលោក ដូចអ្វីដែលព្រះអម្ចាស់ចង់បាន។[68]

គោលការណ៍ទាំងនេះ ទាក់ទងនិងក្រុមជំនុំដែលប្រជុំគ្នា នាំឲ្យសៀវភៅអាចកំបាំងបរិសុទ្ធ ចែងថា «ទាំង កម្មវិធីលៀងព្រះអម្ចាស់ដែលទទួល

---

[66] *THM*, “The communion elements,” 32.

[67] *THM*, “The community extends itself,” 22.

[68] *THM*, “The Meaning of Holy Communion,” 8.

ដោយខ្លួនឯង និងឈៀងចូល គឺផ្ទុយពីធម្មជាតិនៃការប្រជុំគ្នារបស់ពិធីវិសុទ្ធ ដែលជាការប្រារព្ធ នៃសហគមន៍នៃសេចក្ដីជំនឿ។»[69]

**សំ៖** យើងផ្សាយផ្ទាល់កម្មវិធីថ្វាយបង្គំរបស់យើង ដល់សមាជិកដែលចង់ចូលរួម តាមOnline។ តើយើងធ្វើយ៉ាងម៉េចឲ្យគេចូលរួមជាមួយយើងបាន ក្នុងពិធីលៀងព្រះអម្ចាស់?

**ចំ៖** ចំលើយសំរាប់សំនួរនេះ វាស្រដៀងនិងគោលការណ៍សំរាប់អ្នកដែលចង់ទទួលពិធីលៀងព្រះអម្ចាស់ដោយខ្លួនឯង និងអ្នកដែលចង់ឈៀងចូលទទួលពិធីនេះដែរ។

គោលការណ៍គ្រឹះ គឺជាគោលការណ៍ ដែលនំប៉័ង និងពែង ត្រូវបានអធិស្ឋានឲ្យ និងទទួលក្នុង បរិបទដែលក្រុមជំនុំជួបជុំគ្នា។»[70] គោលការណ៍ចេញពីប្រយោគដែលមានក្នុងឯកសារនេះ៖ «ពិធីលៀងព្រះអម្ចាស់ គឺជាការប្រកបគ្នារបស់ក្រុមជំនុំ--ការប្រជុំគ្នារបស់សហគមន៍នៃសេចក្ដីជំនឿទាំងក្នុងតំបន់ និងសកលលោក។ ពិធីនេះមានន័យយ៉ាងជ្រាលជ្រៅសំរាប់ម្នាក់ៗ ពិធីវិសុទ្ធនេះគឺមិនមែនគ្រាន់តែកម្មវិធីឯកជន ប៉ុណ្ណោះទេ។ បទពិសោធន៍នៃការចែករំលែក និងការប្រជុំគ្នា ក្នុងតុព្រះអម្ចាស់ គឺជាធម្មជាតិនៃក្រុមជំនុំ និងជាគំរូដល់ពិភពលោក ដូចអ្វីដែលព្រះអម្ចាស់ចង់បាន។[71] គោលការណ៍ស្រដៀងគ្នាមានក្នុងសេចក្ដីបញ្ចប់ របស់សៀវភៅអាចកំបាំងបរិសុទ្ធ៖ «ពិធីលៀងព្រះអម្ចាស់ គួរត្រូវបានរៀបចំឡើងឲ្យមានទំនាក់ទំនងរវាងតុព្រះអម្ចាស់ និងការរស់នៅបរិសុទ្ធ ទាំងឯកជន និងសហគមន៍... ការប្រកបគ្នាជាមួយក្រុមជំនុំ គឺជាសញ្ញានៃសហគមន៍ និងសេចក្ដីស្រឡាញ់រវាងគ្រីស្ទបរិសទ្ធ ក្នុងសកលលោក។»[72]

---

[69] *THM*, “The community extends itself,” 23.

[70] *THM*, “The community extends itself,” 22.

[71] *THM*, “The Meaning of Holy Communion,” 8.

[72] *THM*, “Holy Communion and ethical Christian discipleship,” 36.

មានសញ្ញាពីរ នៃការប្រកបគ្នាបែបនេះ៖ ទីមួយគឺ ក្នុងនាមជាសហគមន៍ ដែលប្រជុំគ្នា យើងទទួលទាននំប៉័ង និងពែងតែមួយ។ ដូចជាមេសូត្ររបស់យើង រំលឹកយើងថា «ព្រោះមាននំប៉័ងតែមួយ យើងជាច្រើនគ្នា មានរូបកាយតែមួយ» (១កូរិន១០៖១៧)។ សញ្ញាទីពីរ គឺថាយើងមិនទទួលពិធីនេះដោយខ្លួនឯងទេ តែយើងទទួលនំប៉័ង និងពែង ដែលរៀបចំទុកជាពិធីវិសុទ្ធ ពីដៃអ្នកដទៃ។

គោលការណ៍ទាំងនេះស្នើរថា ការដែលយើងចូលរួមក្នុងក្រុមជំនុំOnline ហើយទទួលបានបទពិសោធន៍នៃការទាក់ទងគ្នាខ្លះៗ តែរូបកាយរបស់យើង នៅបែកពីក្រុមជំនុំ ដែលមិនអនុញ្ញាតិ ឲ្យយើងអាចចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ តាមរយៈប្រពន្ធផ្សព្វផ្សាយបែបនេះបានទេ។

ដូចបាននិយាយខាងលើ ព្រះវិហារលើកទឹកចិត្តក្រុមជំនុំ ឲ្យរកវិធីផ្សេងៗក្នុងការចែកចាយដំណឹងល្អ រួមទាំងតាមរយៈបច្ចេកវិជ្ជាទៀតផង។ ក្នុងពេលដែលយើងអាចអញ្ជើញឲ្យគេមើល ការថ្វាយបង្គំក្នុងអ៊ីនធើនេត ឲ្យគេអធិស្ឋានពេលដែលក្រុមជំនុំទទួលពិធីលៀងព្រះអម្ចាស់ ក្រុមប្រឹក្សាលោកអភិបាល ក្នុងឆ្នាំ២០១៣ បានចេញសេចក្តីថ្លែងការមួយ ដែលបញ្ឈប់ការអនុវត្តន៍ទទួលពិធីលៀងព្រះអម្ចាស់Online.[73]

អញ្ចឹង តើយើងធ្វើយ៉ាងម៉េចឲ្យគេចូលរួមជាមួយយើងបាន ក្នុងពិធីលៀងព្រះអម្ចាស់? ដូចគ្នានិងអស់អ្នកដែល «ចង់ប្រកប តែមិនអាចចូលរួមក្នុងការថ្វាយបង្គំ ដោយសារពិការភាព»។ គ្រូគង្វាលអាចយក នំប៉័ង និងពែង ដែលប្រើក្នុងក្រុមជំនុំ ទៅឲ្យពួកគេ។[74] អ្នកដែលនៅឆ្ងាយ ដែលគ្រូគង្វាលមិនអាចទៅដល់ គួរចូលរួមក្នុងក្រុមជំនុំក្នុងតំបន់។

[73] ព័តមានបន្ថែមអំពីការពិភាក្សា និងការប្រឹក្សាយោបល់ សូមចូលមើលវេបសាយនេះ http://www.umc.org/what-we-believe/what-is-the-unitedmethodist-view-of-communion.

[74] *THM*, “The community extends itself,” 22; “Assisting Ministers,” 28; “The Communion elements,” 32.

**សំ៖** បើយើងជឿលើវត្តមានពិតរបស់ព្រះយេស៊ូវគ្រីស្ទ ក្នុងពិធីលៀងព្រះអម្ចាស់ តើយើងគួរនាំយកនំប៉័ងនិងពែង ទៅស្ថានីយ៍រថភ្លើង ហើយចែកដល់អ្នកណាដែលចង់ទទួល?

**ចំ៖** បើតាមទ្រឹស្តី វាសមហេតុផល តែសូមយើងពិចារណាអោយស៊ីជំរៅ។ ទីមួយ ការយល់ឃើញរបស់យូណៃធីតមេថូឌីស្ទ អំពីវត្តមានរបស់ព្រះគ្រីស្ទ ក្នុងពិធីលៀងព្រះអម្ចាស់ មិនបាន«បញ្ជាក់ថា» វត្តមានរបស់ទ្រង់មានក្នុងនំប៉័ង និងពែងនោះទេ។ «ព្រះគ្រីស្ទ មានវត្តមានតាមរយៈសហគមន៍ដែលប្រជុំគ្នាក្នុងព្រះនាមព្រះយេស៊ូវ... តាមរយៈព្រះបន្ទូលដែលបានថ្លែងប្រាប់ និងតាមរយៈនំប៉័ងនិងពែងដែលបានចែករំលែក។»[75] បុគ្គលិកលក្ខណៈសហគមន៍ នៃវត្តមាននេះ ត្រូវបានសង្កត់ធ្ងន់ដោយពាក្យថា «យើងយល់ពីវត្តមានរបស់ព្រះ ជាលក្ខណៈបណ្តោះអាសន្ន និងទំនាក់ទំនង។»[76]

ទីពីរ ពិធីលៀងព្រះអម្ចាស់ មិនត្រូវបានប្រារព្វឡើង ដោយគ្មានការប្រកាលពីដំណឹងល្អក្នុងព្រះគម្ពីរ និងការអធិប្បាយនោះទេ។ ព្រះបន្ទូល និងតុព្រះអម្ចាស់ «ផ្តល់អត្ថន័យឲ្យគ្នាទៅវិញទៅមក ក្នុងកម្មវិធីថ្វាយបង្គំទាំងមូល។ ការធ្វើដោយឡែកពីគ្នា ធ្វើឲ្យបាត់ជីវិតពេញលេញ ក្នុងព្រះវិញ្ញាណ ដែលបានប្រទានមកដោយសេចក្តីជំនឿក្នុងព្រះយេស៊ូវគ្រីស្ទ។»[77] «ការទទួលពិធីលៀងព្រះអម្ចាស់ គឺជាការឆ្លើយតបទៅ និងការបន្តចូលរួមក្នុងព្រះបន្ទូល ដែលបានថ្លែង ប្រាប់។»[78]

គោលការណ៍ទាំងពីរដំបូងនេះ ស្នើរថា ការផ្តល់ព្រះគ្រីស្ទឲ្យអ្នកណាម្នាក់ទាមទារការផ្តល់ឲ្យ មិនមែនគ្រាន់តែនំប៉័ង និងពែងប៉ុណ្ណោះទេ តែជាការផ្តល់ឲ្យនូវសហគមន៍ និងការប្រារព្ធកម្មវិធីនៃព្រះបន្ទូល និងតុព្រះអម្ចាស់ជាមួយសហគមន៍នោះ នៅកន្លែងដែលសហគមន៍នោះប្រជុំ។ នេះមានន័យថា មិនមែនគ្រាន់តែយកនំប៉័ង និងពែង ទៅកន្លែងថ្មីនោះទេ តែត្រូវ

---

[75] *THM*, "The Presence of Christ," 11.

[76] *THM*, "The Presence of Christ," 13.

[77] *THM*, "The Basic Pattern," 18.

[78] *THM*, "The Basic Pattern," 19.

នាំសហគមន៍ថ្វាយបង្គំទាំងមូល។ ដូចដែលបានស្នើរក្នុងការឆ្លើយតបចំពោះសំនួរផ្សេងទៀត ធាតុនៃពិធីលៀងព្រះអម្ចាស់ «ត្រូវបានអធិស្ឋានឲ្យ និងទទួលយក ក្នុងបរិបទនៃការប្រជុំគ្នារបស់ក្រុមជំនុំ។»[79] គោលការណ៍ទាំងនេះ ក៏ចង្អុលបង្ហាញពីសារៈសំខាន់នៃកម្មវិធីព្រះបន្ទូលក្នុងគម្ពីរ និងការអធិប្បាយ ដែលជាផ្នែកចាំបាច់ក្នុងកម្មវិធីតុនៃព្រះអម្ចាស់។

ទីបី មានការខុសគ្នារវាការចែកនំប៉ុងនិងពែងដោយគ្មានការរើសអើង និងពិធីលៀងព្រះអម្ចាស់ជាចំហរ។ សៀវភៅអាចកំបាំងបរិសុទ្ធ បានបញ្ជាក់យ៉ាងច្បាស់ថា ពិធីលៀងព្រះអម្ចាស់ តែងតែចាប់ផ្តើមដោយការអញ្ជើញការសារភាពបាប និងការអត់ទោស។ ការអញ្ជើញនេះសន្មត់ថា អស់អ្នកដែលចូលមកក្នុងតុព្រះអម្ចាស់ ទោះបីគេមកពីនិកាយណាក៏ដោយ គេនឹងចូលមកដោយការឆ្លើយតមក្នុងសេចក្តីជំនឿ ជាការឆ្លើយតបចំពោះសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ ដែលបើកសម្តែងក្នុងព្រះវិហារ។[80] ការចែកនំប៉ុងនិងពែង ដោយគ្មានការរើសអើង ដូចដែលបានស្នើរក្នុងសំនួរនេះ មិនអាចធ្វើឲ្យមានការចូលរួមក្នុងសហគមន៍នៃព្រះបន្ទូល និងតុព្រះអម្ចាស់ ដោយចៀសវាងការអញ្ជើញអោយមានការសារភាព បាប និងសេចក្តីជំនឿ និងមើលរំលងការទទួលខុសត្រូវរបស់ក្រុមជំនុំ ក្នុងការអញ្ជើញអ្នកនោះចូលក្នុង «ដំណើរនៃសេចក្តីជំនឿ និងការរីកចំរើនក្នុងភាពបរិសុទ្ធ។»[81]

---

[79] *THM*, "The community extends itself," 22.

[80] *THM*, "Invitation to the Lord's Table," 13-15.

[81] *THM*, "Invitation to the Lord's Table," 15.

# សំនួរអំពី
# អ្នកចាត់ចែង និងពន្ធកិច្ច

**សំ៖** ខ្ញុំជាគ្រូផ្សាយដំណឹងល្អ (Cerltified Lay Minister) បំរើក្នុងព្រះវិហារនៅជនបទមួយ។ តើខ្ញុំគួរឲ្យប្រធានតំបន់ ឬអែលឌឺ ណាម្នាក់ អធិស្ឋានឲ្យនំបុ័ង និងពែងមុនថ្ងៃអាទិត្យ? តើគេអាចធ្វើតាមទូរសព្ទ័ ឬ Skype បានទេ?



**ចំ៖** សៀវភៅអាចកំបាំងបរិសុទ្ធ បានឆ្លើយសំនួរនេះយ៉ាងច្បាស់៖ ទោះជាធ្វើតាមវិធីណាក៏ដោយ (ទូរសព្ទ័, Skype, FaceTime ឬប្រព័ន្ធបច្ចេកវិជ្ជាផ្សេងទៀត «ការអធិស្ឋានឲ្យនំបុ័ង និងពែងជាមុន មិនសាកសម ហើយផ្ទុយពីគោលលិទ្ធិ និងការយល់ឃើញនៃព្រះគុណរបស់ព្រះ ដែលមានក្នុងពិធិវិសុទ្ធ (Article XVIII, The Articles of Religion, BOD, page 64)»[82]

ការបារម្មណ៍ចំបងមួយ ក្នុងការថ្លែងនេះគឺថា ពិធីអរព្រះគុណ មិនមែនផ្តោតទៅលើ «ការអធិស្ឋានឲ្យនំបុ័ងនិងពែង» ទេ តែគឺផ្តោតលើការប្រជុំគ្នារបស់ក្រុមជំនុំ ជុំវិញតុព្រះអម្ចាស់ ក្នុងការអរព្រះគុណ និងការសរសើរ ដល់ព្រះអម្ចាស់។ «ធាតុរបស់ពិធីលៀងព្រះអម្ចាស់ ត្រូវបានអធិស្ឋានឲ្យ និងទទួលយក ក្នុងបរិបទនៃការប្រជុំរបស់ក្រុមជំនុំ។»[83]

---

[82] *THM*, “The communion elements,” 32.

[83] *THM*, “The community extends itself,” 22).

**សំ៖** តើអ្នកណាដែលមានសិទ្ធិអធិស្ឋានដល់នំប៉័ង និងពែង ដែលមនុស្សបានរៀបចំនៅផ្ទះ ឬត្រូវបានគេផ្ញើរទៅអោយដើម្បីគេអាចប្រើតាមពិធីលៀងព្រះអម្ចាស់តាម Online, ទូរទស្សន៍ ឬផ្សាយតាមវិទ្យុ? តើការនេះធ្វើបានតែអែលឌើ ឬគ្រូគង្វាលតំបន់ដែលមានសិទ្ធិ (Lisence Local Pastor) អាចធ្វើបានដែរ?

**ចំ៖** សៀវភៅអាចកំបាំងបរិសុទ្ធ បញ្ជាក់យ៉ាងច្បាស់ថា «អែលឌើ ឬអ្នកដែលមានសិទ្ធិតាម សៀវភៅវិន័យ អាចចាត់ចែងរាល់ការប្រារព្ធពិធីលៀងព្រះអម្ចាស់។»[84]

ប៉ុន្តែ ដូចដែលយើងបានពិភាក្សាក្នុងចំលើយនៃសំនួរអំពីការចូលរួមក្នុងពិធីលៀងព្រះអម្ចាស់ តាមរយៈផ្សាយផ្ទាល់ (សូមមើលខាងលើ) ការប្រារព្ធពិធីលៀងព្រះអម្ចាស់ និងការ ចូលរួមតាមរយៈការទូរទស្សន៍ និងវិទ្យុ ត្រូវបានហាមឃាត់ដោយក្រុមប្រឹក្សាអភិបាលឆ្នាំ២០១៤ ដែលបានហាមមិនឲ្យមានការអនុវត្តន៍ពិធីវិសុទ្ធតាមOnline ដូច្នេះការរៀបចំនំប៉័ងនិងពែង សំរាប់ធ្វើបែបនេះគឺមិនសាកសមទេ។

**សំ៖** ក្រុមជំនុំខ្ញុំមានឌីកិនដែលធ្វើការជាបុគ្គលិកកន្លះពេល។ តើឌីកិន មានភារៈកិច្ចអ្វីចំពោះការប្រារព្ធពិធីលៀងព្រះអម្ចាស់?

**ចំ៖** សៀវភៅវិន័យ--2012 (¶320) ចែងថា ឌីកិនត្រូវជួយ «អែលឌើ ក្នុងការធ្វើពិធីវិសុទ្ធ» សៀវភៅអាចកំបាំងបរិសុទ្ធ ចែងបន្ថែមថា «ក្នុងការបន្តជាមួយការអនុវត្តន៍ ប្រវត្តិសាស្រ្ត និង អន្តរនិកាយ... តួនាទីនៃឌីកិន គឺការបំរើព្រះបន្ទូល និងតុព្រះអម្ចាស់ ដោយសាកសម រួមមានទាំងការអានដំណឹងល្អ ដឹកនាំការអធិស្ឋានសំរាប់ពិភពលោក ក្រុមជំនុំ និងអ្នកដែលខ្វះខាត ទទួលនំប៉័ង និងពែង មុនពេលអរព្រះគុណ ជួយអែលឌើក្នុងការហុចឲ្យចំណិតនំប៉័ងនិងពែង រៀបចំតុឲ្យមានសណ្តាប់ធ្នាប់ និងប្រាប់មនុស្សឲ្យចេញទៅ

[84] *THM*, "Presiding Ministers: Elders and Licensed Local Pastors," 25-26; Book of Discipline—2012, ¶316.1, 332, 340.2.b.

[85] *THM*, "Assisting Ministers: Deacons and laity," 27.

បំរើ មុនពេលដែលអែលឌឺ ឲ្យពររបស់ព្រះអម្ចាស់។»[85] សៀវភៅដែលមានចំណងជើងថា រស់ក្នុងភាពអាថ៌កំបាំង បានបន្ថែមពីភារៈកិច្ចរបស់ឌីកិនក្នុងតុព្រះអម្ចាស់ថា «ឌីកិនអាចយកនំប៉័ង និងពែង ដាក់លើតុព្រះអម្ចាស់។ ឌីកិនក៏អាចចាក់ទឹកទំពាំងបាយជូចូលក្នុងកូនពែង ហើយរៀបចំឲ្យគ្រប់ការទាំងអស់ មានសណ្តាប់ធ្នាប់ មុនពេលចាប់ផ្តើមពិធីអរព្រះគុណ។ បើសម្ភារៈទាំងអស់មានសណ្តាប់ធ្នាប់ នៅលើតុព្រះអម្ចាស់ ឌីកិនអាចជួយធ្វើជាអ្នកដើរចែកនំប៉័ងនិងពែង ដើម្បីបើកសម្តែងពីភាពធម្មតា ពេញដោយព្រះគុណ អំណាច និងដាក់ក្រណាត់នៅលើតុ។»[86]

**សំ៖** ក្រុមជំនុំខ្ញុំមានគ្រូគង្វាលពីរនាក់ ហើយពួកគាត់ចូលចិត្តចែកតួនាទីគ្នាក្នុងការប្រារព្ធពិធីលៀងព្រះអម្ចាស់។ តើមានវិធីអីដែលល្អសំរាប់ចែកឲ្យមនុស្សពីរនាក់អធិស្ឋាន?

**ចំ៖** សៀវភៅអាថ៌កំបាំងបរិសុទ្ធ មិនបានផ្តល់ចំលើយច្បាស់ចំពោះសំនួរនេះ តែវាផ្តល់គំរុយខ្លះដែរ។ ទីមួយ យើងត្រូវចាំថា ការអរព្រះគុណ គឺជាសេចក្តីអធិស្ឋានបែបសន្ទនា (វាមិនមែនជា «ការប្រមូលផ្តុំ» នៃពាក្យវិសុទ្ធទេ) រវាងគ្រូគង្វាល និងក្រុមជំនុំ។ ដូច្នេះគ្រប់ការចែកសេចក្តីអធិស្ឋាន ត្រូវតែគិតការអធិស្ឋានជាក្រុម។ ការចែកសេចក្តីអធិស្ឋាន ត្រូវតែធ្វើម៉េចឲ្យ សេចក្តីអធិស្ឋាននេះជាសេចក្តីអធិស្ឋានតែមួយ។ ហើយសេចក្តីអធិស្ឋាននេះ មិនត្រូវមានការបែងចែករវាងឌីកិន ឬគ្រូជំនួយទេ។ ដូចសៀវភៅអាថ៌កំបាំងបរិសុទ្ធ ចែងថា «អែលឌឺ ឬគ្រូគង្វាលរៀមច្បង នាំក្រុមជំនុំក្នុងការអធិស្ឋាននៃការអរព្រះគុណ ដែលក្រុមជំនុំទាំងមូលទទួលតួនាទីសកម្ម»[87]

ទីពីរ ដូចក្នុងសៀវភៅអាថ៌កំបាំងបរិសុទ្ធ បញ្ជាក់ថា «គ្រប់អែលឌឺ និងឌីកិនដែលមានវត្តមាន នឹងត្រូវបានអញ្ជើញមក...ឈរជាមួយអ្នកចាត់ចែងក្នុងតុព្រះអម្ចាស់ ហើយជួយក្នុងការចែកនំប៉័ងនិងពែង»[88] សៀវភៅអាថ៌កំបាំង

---

[86] *Living into the Mystery*, 29-30.

[87] *THM*, "The Great Thanksgiving," 22 and "Presiding Ministers," 26.

[88] *THM*, "Presiding Ministers," 26.

បរិសុទ្ធស្នើរថា ទោះបីមានអែលឌឺពីរបីនាក់ មានវត្តមាន គឺមានអែលឌឺម្នាក់ជាអ្នកចាត់ចែងក្នុងតុព្រះអម្ចាស់។

ចំលើយទីមួយ ស្នើរថា អែលឌឺទាំងពីរ ដូរគ្នាក្នុងការចាត់ចែង ប្រារព្ធពិធីលៀងព្រះអម្ចាស់។ ធ្វើដូចនេះ ក្រុមជំនុំនឹងដឹងច្បាស់ថា គ្រប់អែលឌឺ ទោះបីជាថានៈអ្វី ជាគ្រូរៀមច្បង ឬ គ្រូជំនួយ ប្រុស ឬស្រី គឺមានសិទ្ធិចាត់ចែងពិធីវិសុទ្ធក្នុងព្រះវិហារ។ វាក៏ផ្តល់ឪកាសសំរាប់ក្រុមជំនុំ ទទួលបានបទពិសោធន៍ សំឡេងខុសគ្នា និងវិធីនៃការអធិស្ឋានរបស់អែលឌឺទាំងពីរ។

ចំលើយទីពីរ គឺត្រូវឲ្យអែលឌឺទាំងពីរ ត្រូវយកចិត្តទុកដាក់ចំពោះទំរង់ទេវវិទ្យា នៃការអរព្រះគុណ ជាសេចក្តីអធិស្ឋានទោល និងបែងចែកវាឲ្យសម និងទេវវិទ្យានេះ។ ហើយគួរមានការហាត់សម ដើម្បីកុំឲ្យឆ្គងក្នុងការអធិស្ឋាន។ ការប្រើ ពិធីអរព្រះគុណ ក្នុងព្រះបន្ទូល និងតុព្រះអម្ចាស់[89] ជាឧទាហរណ៍ សំរាប់ការបែងចែកដូចខាងក្រោម

អែលឌី១៖ បើកការសន្ទនាតាមរយៈ «ដង្ហើមជីវិត»
អែលឌី២៖ «ពេលយើងបែរចេញ... តាមរយៈហោរា។
អែលឌី១ និង២ ជាមួយគ្នា៖ «ដូច្នេះ ជារាស្ត្ររបស់ទ្រង់ក្នុងផែនដី...»
ទាំងអស់គ្នា៖ «វិសុទ្ធ វិសុទ្ធ វិសុទ្ធ...»
អែលឌី១៖ «ទ្រង់វិសុទ្ធ...ពេលទ្រង់សង្គ្រោះរាស្ត្ររបស់ទ្រង់»
អែលឌី២៖ «ទ្រង់ប្រោសអ្នកឈឺ...ព្រះបន្ទូលទ្រង់ និងព្រះវិញ្ញាណបរិសុទ្ធ»
អែលឌី១៖ «ក្នុងយប់...ទុកជាការរំលឹកដល់ខ្ញុំ»
អែលឌី២៖ «ពេលបរិភោគរួច...ទុកជាការរំលឹកដល់ខ្ញុំ»
អែលឌី១៖ «ដូច្នេះ ក្នុងការនឹកចាំ...អាចកំបាំងនៃសេចក្តីជំនឿ»
ទាំងអស់គ្នា៖ «ព្រះគ្រីស្ទបានសុគត...»
អែលឌី១៖ «ចាក់បង្ហូរព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់...ដោយលោហិតទ្រង់»
អែលឌី២៖«ដោយព្រះវិញ្ញាណទ្រង់...នៅការជប់លៀងនៅនគរស្ថានសួគ៌»
អែលឌី១និង២ ជាមួយគ្នា៖ «តាមរយៈព្រះយេស៊ូវគ្រីស្ទ...»
ទាំងអស់គ្នា៖ «អាមែន»

ការបែងចែកនេះតម្រូវឲ្យអែលឌឺទាំងពីរ ហាត់សមដោយប្រុងប្រយ័ត្ន ដើម្បីឲ្យគ្រប់យ៉ាងរលូន និងពេញដោយសេចក្តីអធិស្ឋាន។

---

[89] *United Methodist Hymnal*, 9-10; *United Methodist Book of Worship*, 36-38.

# សំនួរពី
# ការយកចិត្តទុកដាក់ចំពោះធាតុនៃពិធីវិសុទ្ធ

**សំ៖** តើពេលណាដែលយើងគួរយកធាតុនៃពិធីវិសុទ្ធដែលបានអធិស្ឋានឲ្យហើយ ទៅឲ្យអ្នកដែលមិនអាចមកចូលរួមពិធីលៀងព្រះអម្ចាស់? តើចុងសប្តាហ៍បានទេ? ឬចុងខែ? តើយើងអាចបង្កកធាតុនៃពិធីវិសុទ្ធ ដើម្បីទុកបានយូរដែរឬទេ?

**ចំ៖** សៀវភៅអាចកំបាំងបរិសុទ្ធមិនបានឆ្លើយសំនួរនេះដោយច្បាស់នោះទេ។ តែវាបានចែងពីគោលការណ៍ដែលថា «តុព្រះអម្ចាស់អាចរៀបចំបានក្នុងពេលសមរម្យ ដើម្បីអាចឲ្យអ្នកដែលមិនអាចចូលរួមដោយសារអាយុ ជំងឺ ឬស្ថានភាពស្រដៀងនេះ។»[90] ភាពច្បាស់លាស់ក្នុងគោលការណ៍នេះគឺថា ការយកនំប៉័ង និងទឹកទំពាំងបាយជូ ទៅឲ្យអ្នកដែលមិនអាច ចូលរួមបាន គឺជាការបន្ថែមលើការប្រារព្ធពិធីរបស់សហគមន៍ជួបជុំ។ វាមិនមែនជាទំរង់បែប «រក្សាទុក» ពិធីវិសុទ្ធ ឬជា «របស់សល់» នោះទេ។ អ្វីដែលយើងចែករំលែក មិនមែនគ្រាន់តែជា នំប៉័ង និងទឹកទំពាំងបាយជូប៉ុណ្ណោះទេ តែវាជាការជួបជុំជាមួយព្រះគ្រីស្ទ និងសមាជិកក្រុមជំនុំផងដែរ។ ក្នុងការជួបជុំគ្នានេះ យើងប្រារព្ធពិធីជាមួយគ្នា ក្នុងសហគមន៍ ដែលបានជួបជុំ ជុំវិញតុព្រះអម្ចាស់ ដែលយើងបន្ថែមដល់អ្នកដែលមិនអាចចូលរួមដោយអចេតនា។

ដូច្នេះ យើងគួរនាំយកធាតុនៃពិធីវិសុទ្ធទៅឲ្យគេ នៅថ្ងៃដដែល ឬយ៉ាងយូរបំផុត មួយថ្ងៃបន្ទាប់ បើនំប៉័ង និងទឹកទំពាំងបាយជូរមិនទាន់ខូច។ បើយូរជាងនេះ នោះវាមិនបំពេញតាមអត្ថន័យដែលយើងចង់បាននោះទេ។ បើយើងមិនអាចធ្វើបានទាន់ពេល គ្រូគង្វាលគួរៀបចំពេលផ្សេងសំរាប់ជួបសមាជិក ដើម្បីធ្វើពិធីលៀងព្រះអម្ចាស់។ (សូមមើលសៀវភៅ ការបន្ថែមតុព្រះអម្ចាស់ ដែលសរសេរដោយលោក Mark Stamm ដែលមានក្នុងតារាង «សៀវភៅសំរាប់អានផ្សេងទៀត» ដើម្បីយល់ពីការពិភាក្សានៃពន្ធកិច្ចនេះ។)

---

[90] *THM*, “The Community extends itself,” 22 and “The Communion Elements,” 32.

**សំ៖** តើគួរធ្វើយ៉ាងម៉េច ចំពោះនំប៉័ង និងទឹកទំពាំងបាយជូរ ដែលនៅសល់?

**ចំ៖** សៀវភៅអាចកំបាំងបរិសុទ្ធ បង្ហាញពីគោលការណ៍ចំបង អំពីនំប៉័ង និងទឹកទំពាំងបាយជូរ ដែលនៅសល់។ «យើងគួរមានការគោរពចំពោះ នំប៉័ង និងទឹកទំពាំងដែលបានអធិស្ឋានឲ្យរួចហើយ។ វាជាអំណោយទានមកពីព្រះអម្ចាស់ ហើយក្នុងពិធីអរព្រះគុណ នំប៉័ងនិងទឹកទំពាំងបាយជូ គឺជា «រូបកាយ និងលោហិតរបស់ព្រះយេស៊ូវ» (សៀវភៅចំរៀង ទំព័រ១០)[91]។ ក៏មានការពន្យល់បន្ថែមទៀតក្នុងសៀវភៅថ្វាយបង្គំ (ទំព័រ៣០)៖ «ចំពោះនំប៉័ង និងទឹកទំពាំងបាយជូ ដែលនៅសល់ យើងគួររៀបចំឲ្យដូចជាអំណោយទានមកពីព្រះ និងការគោរពចំពោះគោលបំណងរបស់នំប៉័ងនិងទឹកទំពាំងបាយជូ។»

ដូច្នេះយើងគួរធ្វើយ៉ាងនេះ៖ ទីមួយ, ចំពោះនំប៉័ង និងទឹកទំពាំងបាយជូ ដែលនៅសល់ គួរតែយកចូលទៅក្នុងបន្ទប់វិញ ដើម្បីឲ្យចាស់ទុំរៀបចំសំរាប់នាំទៅឲ្យអ្នកដែលមិនបានមកចូលរួមក្នុងកម្មវិធី។

ទីពីរ ដោយសារនេះជាអំណោយទានអាហារ «គ្រូគង្វាល និងអ្នកដទៃទៀត ដែលគ្រូគង្វាលរើស គួរបរិភោគអោយអស់ បន្ទាប់ពីកម្មវិធី។»[92]

ចុងក្រោយ យើងអាច «បញ្ជូនវាទៅដីវិញ ដោយចាក់ កប់ បាច ឬដុត»[93] យើងមិនគួរចាក់វាចូលលូ ឬបោះចោលចូលធុងសំរាមទេ។ សៀវភៅ រស់នៅក្នុងអាចកំបាំង ប្រាប់ពីចំនុចសំខាន់មួយ៖ «ការដែលយើងបញ្ជូនវាទៅដីវិញ អាចជាសក្ខីកម្មយ៉ាងពិសេសមួយ។ យើងណែនាំថា នំប៉័ង និងទឹកទំពាំងបាយជូ ដែលនៅសល់ គួរតែបញ្ជូនទៅដីវិញ ដោយចំណែកតូចៗ។ បើមានដុំនំប៉័ងធំៗ នៅលើធ្លាព្រះវិហារ ឬក្នុងសួនបន្លែ នោះដូចជាមិនសមគ្នែក ហើយនាំឲ្យគេគិតថា យើងខ្ជះខ្ជាយ។ ដើម្បីចៀសវាងការនេះ យើងគួររៀបចំនំប៉័ង និងទឹកទំពាំងបាយជូរ អោយល្មមក្នុងការប្រើប្រាស់ កុំឲ្យសល់ច្រើនពេក។»[94]

---

[91] *THM*, “The Communion elements,” 31.

[92] *THM*, “The Communion elements,” 32.

[93] *THM*, “The Communion elements,” 32.

[94] *Living into the Mystery*, 51.




**សំ៖** យើងប្រារព្ធពិធីលៀងព្រះអម្ចាស់ជាមួយក្រុមយុវជន ក្នុងថ្ងៃចុងក្រោយ នៃកម្មវិធីសំរាក (retreat)។ តើយើងអាចប្រើទឹកផ្លែឈើ និងនំដូណាត់ (Donut) ជំនួសទឹកទំពាំងបាយជូ និងនំប៉័ង បានទេ?

**ចំ៖** ជួនកាលយើងអាចមិនប្រើទឹកទំពាំងបាយជូ និងនំប៉័ងដោយសារបរិបទវប្បធម៌ តែនេះគឺជាការសំរេចចិត្តរបស់ក្រុមជំនុំ។ សៀវភៅអាចកំបាំងបរិសុទ្ធ បញ្ជាក់ពីសារៈសំខាន់នៃ «ប្រវត្តិនៃក្រុមជំនុំសកល» ដែលមានការប្រើនំប៉័ងនិងទឹកទំពាំងបាយជូ។ និយាយពីនំប៉័ង  សៀវភៅអាចកំបាំងបរិសុទ្ធ ចែងថា «យោងតាមព្រះបន្ទូលរបស់ព្រះគ្រីស្ទ និងប្រពៃណីគ្រីស្ទាន ក្រុមជំនុំប្រើនំប៉័ងសំរាប់ពិធីលៀងព្រះអម្ចាស់»។ នេះមានន័យថា នំប៉័ង «អាចធ្វើពីគ្រាប់ធញ្ញជាតិដែលមាន» ហើយត្រូវ «មានរូបរាង និងរស់ជាតិ ដូចនំប៉័ង»។ វាអាចមានតំបែរ ឬគ្មាន តែវាគួរជានំប៉័ងសាប (អត់មានទឹកស្ករសណ្តែកដី ទំពាំងបាយជូក្រៀម ថៃមព័រ ឬបន្ថែមអ្វីផ្សេងពីលើទេ)។ សៀវភៅអាចកំបាំងបរិសុទ្ធ ក៏មានចែងគោលការណ៍នៃទឹកទំពាំងបាយជូស្រដៀងគ្នានេះដែរ៖ «យោងតាមព្រះបន្ទូលរបស់ព្រះគ្រីស្ទ និងប្រពៃណីគ្រីស្ទាន ក្រុមជំនុំប្រើទឹកទំពាំងបាយជូ  សំរាប់ពិធីលៀងព្រះអម្ចាស់» ក្រុមជំនុំជាច្រើន ទាំងកាតូលិក និងប្រូតេស្តង់ តែងតែប្រើស្រាទំពាំងបាយជូរ តែយូណៃធីតមេថូឌីស្ទ តាំងពីសត្តវត្សទី១៩មក ប្រើទឹកទំពាំងបាយជូរ។[95]

---

[95] *THM*, “The Communion Elements,” 30-31.

# ផ្នែកព្រលឹងវិញ្ញាណនៃពិធីលៀងព្រះអម្ចាស់

តើពិធីលៀងព្រះអម្ចាស់ មានន័យដូចម្ដេច ចំពោះយុវ័ណៃធីតមេថូឌីស្ទ? ក្នុងតុព្រះអម្ចាស់ យើងត្រូវបានបំផ្លាស់បំប្រែ តាមភាសានៃការអរព្រះគុណ និងការនឹកចាំ។ យើងទទួលបានបទពិសោធន៍នៃសញ្ញាឲ្យយើងស្រឡាញ់ព្រះ និងអ្នកជិតខាង។ យើងទទួលបានសញ្ញានៃសេចក្ដីស្រឡាញ់របស់ព្រះមកលើយើង ទោះបីជាជួនកាលយើង មានអារម្មណ៍យើងមិនសាកសមចំពោះសេចក្ដីស្រឡាញ់នោះក៏ដោយ។ ការអរព្រះគុណ ការចូលរួមក្នុងតុព្រះអម្ចាស់ និងការចែករំលែកដល់គ្នា ផ្ដល់នូវរូបភាពមួយដែលបញ្ជាក់ថាយើងត្រូវបានត្រាស់ហៅឲ្យធ្វើអ្វីថ្ងៃនេះ ហើយនិងថ្ងៃខាងមុខ។ ទោះបីយើងហៅពិធីលៀងព្រះអម្ចាស់ថា Eucharist, Lord's Supper, or Holy Communion យើងទទួលបានបទពិសោធន៍នៃសេចក្ដីសន្យានៃការបង្កើតថ្មីរបស់ព្រះ ទទួលបានសារៈប្រយោជន៍ នៃជីវិតជាសិស្សរបស់ព្រះគ្រីស្ទ និងត្រូវបានបញ្ជូនឲ្យទៅ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីធ្វើជារូបកាយរបស់ព្រះគ្រីស្ទ ក្នុងបេសកកម្មក្នុងពិភពលោក។

# សៀវភៅផ្សេងទៀតសំរាប់អាន


*Eucharist: Christ's Feast With the Church*, by Laurence Hull Stookey (Nashville: Abingdon Press, 1993).

*Let Every Soul Be Jesus' Guest,* by Mark Stamm (Nashville: Abingdon, 2006).

*Living into the Mystery: A United Methodist Guide for Celebrating Holy Communion* (Nashville: General Board of Discipleship, 2007).

*The Worship Resources of the United Methodist Hymnal*, by Hoyt Hickman (Nashville: Abingdon, 1989).

*This Holy Mystery: A United Methodist Understanding of Holy Communion* (Nashville: General Board of Discipleship, 2004)

*This Holy Mystery: A United Methodist Understanding of Holy Communion Study Guide,* by Gayle Carlton Felton (Nashville: General Board of Discipleship, 2005)

*This Holy Mystery: A United Methodist Understanding of Holy Communion A Study Guide for Children,* by Carolyn Tanner (Akron: OSL Publications, 2006).

"The Duty of Constant Communion," by John Wesley, in *The Works of John Wesley*, Volume 3, edited by Albert C. Outler (Nashville: Abingdon Press, 1986), pages 427-39.

"The Means of Grace," by John Wesley, in *The Works of John Wesley*, Volume 1, edited by Albert C. Outler (Nashville: Abingdon Press, 1984), pages 376–97.

*Worshiping With United Methodists: A Guide for Pastors and Church Leaders*, by Hoyt L. Hickman (Nashville: Abingdon Press, 1996).

*Worship Matters* (Volumes I and II), edited by E. Byron Anderson (Nashville: Discipleship Resources, 1999).

# អំពីអ្នកនិពន្ធ

Rev. Dr. E. Byron (Ron) Anderson គឺជាសាស្ត្រាចារ្យផ្នែកថ្វាយបង្គំ (Styber Professor of Worship) នៅសកលវិទ្យាល័យ Garrett-Evangelical Theological Seminary, ទីក្រុង Evanston រដ្ឋ Illinois. Dr. Anderson គឺជាអែលឌើក្នុងនិកាយយូណៃធីតមេថូឌីស្ទ ក្នុង Minnesota Annual Conference.

DISCIPLESHIP MINISTRIES
The United Methodist Church

1908 Grand Avenue, Nashville, TN 37212 · UMCdiscipleship.org · 877.899.2780